អ្នកស្រាវជ្រាវភាគច្រើនយល់ថា ខ្មែរពុំមានរូបិយវត្ថុទេ រហូតដល់រវាងសតវត្សទី១៦ ទើបគេឃើញកាក់ដំបូងៗរបស់ខ្មែរ។ ពាណិជ្ជកម្មពេលនោះធ្វើឡើងតាមរបៀបបុរាណ គឺគេដោះដូរពីរបស់មួយទៅមួយដោយពុំទាន់មានប្រាក់កាក់ ឬជារូបិយវត្ថុនៅឡើយទេ។ ការអះអាងទាំងនេះក៏មិនមែនគ្មានសេចក្តីជំទាស់នោះទេ។ *Punjabhan* ដែលជាអ្នកស្រាវជ្រាវជាតិសៀមសរសេរថា ជនជាតិអាយជាម្ចាស់ស្រុកនៅតំបន់នេះមានរូបិយវត្ថុរួចមកហើយ ក្នុងនោះគាត់ពោលអះអាងពីកាក់ប្រាក់នៃអាណាចក្រហ្វូណននិងទ្វារវតីជាដើម[៤៣]។ ការសន្និដ្ឋានរបស់គាត់ធ្វើឡើងដោយសំអាងលើកាក់មួយចំនួនដែលប្រទះឃើញនៅស្ថានីយ៍អូកែវនិងនៅស្ថានីយ៍មួយចំនួននៅក្នុងទឹកដីប្រទេសថៃឡង់ដ៍សព្វថ្ងៃ ជាពិសេសនៅតំបន់ *U-thong* ដែលជាផ្នែកមួយនៃអាណាចក្រហ្វូណននាពេលនោះ។ កាក់ទាំងនោះធ្វើពីប្រាក់ សំណប៉ាហាំង និងទង់ដែង ហើយដែលធ្វើឡើងដោយចាក់លើពុម្ពធ្វើពីដីឬពីថ្ម។ ទោះបីយ៉ាងណា គេកម្រប្រទះកាក់ប្រភេទនេះនៅតាមស្ថានីយ៍ផ្សេងទៀតណាស់។ *Punjabhan* បានកត់សម្គាល់ថាកាក់ហ្វូណនមានពីរប្រភេទ។ ប្រភេទដែលរកឃើញនៅ *U-thong* មានកម្រាសក្រាស់និងសំប៉ែតល្អ ហើយប្រហែលធ្វើដោយជាងប្រាក់ក្នុងរាំង និងមួយប្រភេទទៀតរកឃើញនៅតាមភូមិតូចៗខាងក្រៅ *U-thong* ដែលមានរាងមូលខូងដក់កណ្តាលដូចស្វិកឈូកនិងស្តើងជាងកាក់នៅ *U-thong* ហើយដែលគេជឿថាធ្វើដោយជាងទូទៅ។ កាក់ទាំងនោះមានត្រាពីរប្រភេទផ្សេងគ្នា។ ប្រភេទទីមួយមានរូបព្រះអាទិត្យឬចំណិតព្រះច័ន្ទនៅមួយចំហៀង ហើយមួយចំហៀងទៀតមានអក្សរទេពនាគរី ឬរូបគ្រុឌចាប់នាគ ឯប្រភេទទីពីរមានរូបខ្យងស័ង្ខមួយចំហៀងនិងមួយចំហៀងទៀតមានរូបមណ្ឌបដែលខាងក្រោមមានរូបត្រី។ លោកមីសែល ត្រាណេ ដែលចាប់អារម្មណ៍ខ្លាំងលើបុរាណវត្ថុខ្មែរនៅសម័យមុនប្រវត្តិសាស្ត្រ និងដើមប្រវត្តិសាស្ត្រ ហើយមានសមុច្ច័យវត្ថុទាំងនោះផ្ទាល់ខ្លួនផង បានធ្វើការសិក្សានិងបោះពុម្ពសៀវភៅមួយចំនួន។ ក្នុងសៀវភៅដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាៈ ការបង្កើតរដ្ឋខ្មែរ"

៤៣ *Punjabhan, 2534 B.E.: 15.*



បោះពុម្ពផ្សាយឆ្នាំ២០០២ លោកបានបង្ហាញការមិនឯកភាពនឹងទ្រឹស្តីដែលថាខ្មែរពុំមានលុយចាយ តែក៏យល់ស្របថាខ្មែរធ្វើពាណិជ្ជកម្មតាមរបៀបដោះដូរទំនិញនេះ។ គាត់អះអាងថា គេធ្លាប់ចាយរូបិយវត្ថុបុរាណជាកាក់មាស ប្រាក់ សំរឹទ្ធិ សំណ ឬគេប្រើកាក់ចិនជាមធ្យោបាយ[៤៤]។ ក្នុងនោះគាត់ទាញយកសេចក្តីខ្លះដែលមានក្នុងសិលាចារឹក *Ka. 40* មកគាំទ្រសម្មតិកម្មរបស់ខ្លួន។ ក៏ប៉ុន្តែលោក *Michael Vickery* ដែលនៅធ្វើការសិក្សាយ៉ាងហ្មត់ចត់ស្តីអំពីសេដ្ឋកិច្ចនិងសង្គមខ្មែរនាសម័យមុនអង្គរ ដោយផ្អែកលើប្រភពពត៌មានផ្សេងៗ ក្នុងនោះមានឯកសារចិនផងនិងពិនិត្យសិលាចារឹកម្តងមួយៗបានអះអាងបញ្ជាក់ថា ខ្មែរពុំទាន់មានរូបិយវត្ថុសម្រាប់ចាយវាយដោះដូរទំនិញទេ។ គេទិញលក់តាមវិធីដោះដូរដោយវត្ថុមួយទៅវត្ថុមួយទៀត។ ក៏ប៉ុន្តែក៏បាននិយាយដែរថា បើការដោះដូរធំៗ គេប្រើមាសនិងប្រាក់ ហើយគេបង់ពន្ធអាករជាវត្ថុមានតម្លៃផ្សេងៗមានមាសប្រាក់ ឬគ្រឿងក្រអូបជាដើម[៤៥]។ កំណត់ហេតុចិននៅសតវត្សទី៣ ក៏បញ្ជាក់ដូច្នេះដែរថា ហ្វូណនពុំមានរូបិយវត្ថុរបស់ខ្លួនទេ។ ទន្ទឹមនឹងនេះសិលាចារឹកជាច្រើនមាននិយាយពីមាសនិងប្រាក់ដែលគេប្រើសម្រាប់បង់ថ្លៃទំនិញ។ រហូតដល់សម័យអង្គរ ក៏នៅតែពុំមានទិន្នន័យអំពីរូបិយវត្ថុសម្រាប់ចាយវាយ។ កំណាយនានានៅតំបន់អង្គរដែលជារាជធានីពីសតវត្សទី៩ដល់១៤ហើយដែលអ្នកស្រាវជ្រាវប៉ាន់ស្មានថាមានប្រជាជនរស់នៅប្រមាណជាងមួយលាននាក់ផងនោះ ក៏គេពុំដែលប្រទះឃើញកាក់ ឬវត្ថុណាមួយដែលអាចឲ្យគេសង្ស័យថាជារូបិយវត្ថុទាល់តែសោះ។ លោកជីវ តាក្វាន់ ពោលអះអាងយ៉ាងដូច្នេះថាៈ

> "...ប្រទេសនេះពុំមានរូបិយវត្ថុទេ។ ...ផ្សារមាននៅតាមផ្លូវពុំមានប្រក់ដំបូលអ្វីត្រឹមត្រូវទេ។ ក្នុងការទូទាត់ទំនិញតូចតាច គេធ្វើតាមវិធីដោះដូរជាមួយវត្ថុ មួយទៀតមានដូចជាស្រូវ គ្រាប់

៤៤ មីសែល ត្រាណេ ២០០២ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាៈ ការបង្កើតរដ្ឋខ្មែរ" រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទ.៤៥។

៤៥ *Vickery 1996, pp. 288-89.*

ធញ្ញជាតិ វត្ថុផ្សេងៗនាំពីស្រុកចិន បន្ទាប់មកកំណាត់សំពត់ មានតម្លៃជាដើម។ ក្នុងការទូទាត់របស់ធំៗគេប្រើជាមាសនិង ប្រាក់...»[៥៦]

បើដូច្នេះមែន មាសនិងប្រាក់ដែលរៀបរាប់នេះក៏នៅតែពុំមែនជារូបិយវត្ថុ តែជាលោហធាតុ ដែលគេអាចប្រើតាងឲ្យតម្លៃណាមួយ។ ការសន្មតយកលោហធាតុប្រើជាគ្រឿងដោះដូរនេះមានរហូតដល់ដែកទៀតផង។ ការទូទាត់ទំនិញរបៀបនេះមាននិយាយច្រើនក្នុងសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរ។ ការទិញលក់ដីធ្លី ស្រែ ឬលោះខ្ញុំ គេគិតជារបស់ផ្សេងៗដែលមានតម្លៃ ដូចជាសត្វពាហនៈ រហូតដល់មាសនិងប្រាក់ជាលោហធាតុនិងជាគ្រឿង។ តើ“មាស” និង “ប្រាក់” ដែលបញ្ជាក់ក្នុងសិលាចារឹកទាំងនោះគ្រាន់តែជាដុំលោហធាតុយ៉ាងសាមញ្ញ ឬមានសភាពជារូបិយវត្ថុដែលគេផលិតតាមទម្ងន់ផ្សេងៗជាឯកតាសម្រាប់គិតក្នុងការទូទាត់ទិញលក់ឬយ៉ាងណា? ដរាបណាគេពុំរកឃើញបុរាណវត្ថុណាមួយជាកាក់ ឬមានភិនភាគស្រដៀងនោះទេ គេនៅតែមិនអាចពោលអះអាងបាននៅឡើយ។ ក៏ប៉ុន្តែយើងគួរយកបញ្ហានេះមកពិនិត្យពិចារណាដែរ។ មាសប្រាក់ទាំងនេះអាចជារូបភាពដំបូងៗដែលនាំដល់ការបង្កើតរូបិយវត្ថុ។ ផ្ទាំងចម្លាក់ជាច្រើនអន្លើនៅប្រាសាទបាយ័ន្តនិងបន្ទាយឆ្មារក៏បង្ហាញពីទិដ្ឋភាពផ្សារលក់ដូរ ដែលគួរតែមានរូបិយវត្ថុសម្រាប់ទូទាត់។ រូបលេខ៧០ចម្លាក់នៅប្រាសាទបាយ័ន្ត បង្ហាញពីអ្នកលក់កំពុងថ្លឹងអ្វីមួយនឹងជញ្ជីងបោ៉ល រីឯរូបលេខ៧១នៅប្រាសាទបន្ទាយឆ្មារ បង្ហាញពីតូបលក់កំណាត់សំពត់។ ផ្ទាំងចម្លាក់ទាំងនេះក៏បង្ហាញឲ្យឃើញពីតួអង្គមនុស្សនិងទេពនានាមានពាក់អលង្ការយ៉ាងច្រើនដែលអាចឲ្យគេយល់បានភ្លាមថា ប្រទេសកម្ពុជាពេលនោះមានសម្បត្តិស្តុកស្តម្ភនិងរីកចម្រើនថ្កុំថ្កើង។ ជាក់ស្តែងឃើញថាដូច្នេះមែន។ មកដល់រវាងសតវត្សទី១២និងទី១៣ អាណាចក្រអង្គរវាតអំណាចធំទូលាយទាំងសេដ្ឋកិច្ច ទាំងនយោបាយ មួយភាគធំនៃឥណ្ឌូចិន។

[៥៦] Zhou 1993, p. 43.





រូបលេខ៧០៖ ទិដ្ឋភាពមួយក្នុងផ្សារនៅសតវត្សទី១២ (ចម្លាក់នៅប្រាសាទបាយ័ន្ត)។



រូបលេខ៧១៖ ទិដ្ឋភាពមួយក្នុងផ្សារនៅសតវត្សទី១២ (ចម្លាក់នៅប្រាសាទបន្ទាយឆ្មារ)។

រហូតដល់រវាងសតវត្សទី១៥ ទើបយើងមានទិន្នន័យខ្លះៗពីរូបិយវត្ថុសម្រាប់ចាយវាយនៅពេលនោះ ហើយអាចមានឥទ្ធិពលពីសៀម។ បើយោងតាមព្រះរាជពង្សាវតារខ្មែរ ហ្លួងព្រះស្តេចកនបានចាត់ចែងឲ្យបោះពុម្ពប្រាក់សម្រាប់ចាយវាយរបៀបជា “ប្រាក់ស្លឹង” ធ្វើពីមាសនិងប្រាក់ដែលមានរូបនាគម្នាង។ ទោះបីយ៉ាងណា រហូតដល់ពេលនេះគេពុំដែលប្រទះឃើញកាក់ប្រភេទនោះទាល់តែសោះ។ រហូតដល់រាជ្យក្រោយមករវាងគ.ស.១៥៦៤ ទើបយើងមានភស្តុតាងពីកាក់ប្រាក់[៥៧]។

លោក *Henri Mouhot* ដែលធ្វើដំណើរទៅដល់អង្គរនៅឆ្នាំ១៨៦០ បានអះអាងថាគាត់រើសបានកាក់ប្រាក់នៅទីនោះដែលមានរូបរាងដូចគ្នានឹងកាក់ប្រាក់ដែលគេចាយនៅដែនដីកូសាំងស៊ីន ដែលគេហៅថាប្រាក់ណែន។ កាក់ដែលគាត់រកឃើញនៅអង្គរនោះធំជាង។ ព្រះបាទអង្គឌួងក្រោយឡើងសោយរាជ្យពេញលេញ ព្រះអង្គចាត់ចែងឲ្យបោះប្រាក់ចាយនៅរវាងពាក់កណ្តាលសតវត្សទី១៩ ដែលមានរូបប្រាសាទនៅម្ខាង និងហង្សនៅម្ខាងទៀត (រូបលេខ៧២)។ តឹកតាងសំខាន់មួយអំពីការបោះពុម្ពប្រាក់នេះ គឺបុរាណវត្ថុមួយដែលសេសសល់នៅអតីត

[៥៧] អាដេម៉ា ឡឺក្លែរ ២០០៦ ទ.២១៩។

រាជធានីឧត្តុង្គដល់សព្វថ្ងៃ ហើយដែលអ្នកស្រុកនៅតំបន់នេះហៅថា "ពុម្ពប្រាក់" ហើយដែលគេគោរពបូជាដូចអ្នកតាដែរ (រូបលេខ៧៣)។ ក្រោយពីនោះមក យើងមានកាក់ដែលបោះពុម្ពនៅក្នុងរាជ្យព្រះករុណាព្រះបាទនរោត្តម (រូបលេខ ៧៤) និងព្រះស៊ីសុវត្ថិ (រូបលេខ៧៥)។



រូបលេខ៧២៖ កាក់ប្រាក់បោះឆ្នាំ១៨៤៧ជំនាន់ព្រះបាទអង្គឌួង (រូបថត៖ Darryl Collins)។



រូបលេខ៧៣៖ ពុម្ពប្រាក់ដែលនៅសល់ក្នុងអតីតក្រុងឧត្តុង្គ ហើយដែលគេបូជាជាអ្នកតា។




រូបលេខ៧៤៖ កាក់ប្រាក់បោះតាយនៅជំនាន់ព្រះបាទនរោត្តម (រូបថត៖ Darryl Collins)។



រូបលេខ៧៥៖ កាក់ប្រាក់បោះតាយនៅជំនាន់ព្រះបាទស៊ីសុវត្ថិ (រូបថត៖ Darryl Collins)។



## ៣. គ្រឿងប្រាក់៖ ទ្រព្យសម្បត្តិប្រចាំគ្រួសារខ្មែរ

ប្រជាជនខ្មែរជាង៨០ភាគរយជាកសិករ នៅសល់ពីនេះជាអ្នករាជការ អ្នកជំនួញតូចធំ កម្មករ និងសិប្បករ ដែលច្រើនតែរស់នៅតាមទីក្រុងនិងប្រជុំជនធំៗ។ ទ្រព្យធនដែលអ្នកស្រែ ឬអ្នកចម្ការនីមួយៗមានជាដីសម្រាប់ការដាំដុះ សត្វពាហនៈ និងសម្ភារៈសម្រាប់ប្រកបកិច្ចការស្រែចម្ការរបស់ខ្លួន។ ផលដែលទទួលបានពីស្រែចម្ការ គេយកទៅលក់ឬដោះដូរយករបស់ប្រើប្រាស់សំខាន់ដែលគេមិនអាចធ្វើខ្លួនឯងបាន ដូចជាកំណាត់សំពត់ ខោអាវ ចានក្បាន គ្រឿងទេសខ្លះៗមានអំបិលប្រហុក ទឹកត្រីៗល។ សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។ អ្វីដែលខ្ញុំនិយាយមកដល់ពេលនេះ គឺជាវដ្តជីវិតនៃគ្រួសារនីមួយៗដែលស្ដាប់ទៅហាក់ដូចជាគ្រួសារខ្មែរគ្មានទ្រព្យធនអ្វីលើសពីនេះសម្រាប់គ្រួសារនីមួយៗឲ្យមានលំនឹង។ តើទ្រព្យធនអ្វីជាទីលំនឹងនៃគ្រួសារខ្មែរ ជាពិសេសសម្រាប់ដោះស្រាយពេលមានកិច្ចការចាំបាច់ ឬពេលមានអាសន្នអន់ក្រ? តើកូនចៅដែលត្រូវតពូជផៅសន្តានទៅមុខទៀត មានអ្វីជាកេរ្តិ៍មត៌កដើម្បីជាទុនអាចឲ្យគេរៀបចំគ្រួសារថ្មីមួយបាន? យើងដឹងថាដីជាអចលនទ្រព្យយ៉ាងសំខាន់ ដូចមានពាក្យដែលអ្នកស្រុកលើតែងនិយាយថា "អ្នកធ្វើចម្ការព្រៃផុតរស់មិនមានលំនឹង ត្បិតគ្មានដីមួយដុំ គ្មានត្រុំមួយដើមទុកជាមត៌កឲ្យកូន មិនដូចអ្នកស្រែចម្ការស្រុកក្រោម"។ ដូច្នេះគ្រួសារខ្មែរត្រូវមានការវិនិយោគអ្វីមួយប្រចាំគ្រួសារឲ្យបានជាទីលំនឹង ឯការវិនិយោគនោះ គឺគ្មានអ្វីក្រៅពីឆ្លៀតយកផលដែលបានពីស្រែចម្ការទៅដោះដូររបស់របរមានតម្លៃផ្សេងៗមានអលង្ការមាស គ្រឿងប្រាក់ ឬកំណាត់សំពត់ហូល ផាមួងមករក្សាទុកជាទ្រព្យជាទីសំអាង។

ពីសម័យបុរាណរហូតដល់ប៉ុន្មានទសវត្សមុននេះ ប្រព័ន្ធធ្វើពាណិជ្ជកម្មតាមរូបភាពដោះដូរពីទំនិញមួយទៅមួយឃើញថាគេនៅអនុវត្តខ្លាំងក្លានៅឡើយ។ ហេតុនេះបានជាយើងមានពាក្យថា "ជំនួញជួញប្រែ" ឬ "ជំនួញជួញដូរ" ត្បិតក្នុងការធ្វើជំនួញ យើងធ្វើការដោះដូរជាគោល។ សព្វថ្ងៃសោត យើងនៅតែឃើញមានការដោះដូររបៀបនេះនៅឡើយ ជាពិសេសសម្រាប់អ្នកស្រែ។ រាល់ឆ្នាំ អ្នកស្រែតែងដឹកស្រូវមកដោះដូរនឹងត្រីប្រហុក ឬអំបិលនៅរដូវនេសាទម្ដងៗ។ រីឯស្មូនឆ្នាំងនៅខេត្តកំពង់ឆ្នាំងតែងដឹកក្អមឆ្នាំងដែលផលិតហើយតាមរទេះគោដើរលក់ទូទាំងខេត្តមួយ

ទៅមួយ ហើយដែលភាគច្រើនក្រោមរូបភាពដោះដូរស្រូវអង្ករជាមួយអ្នកស្រែ។ ប្រមាណមួយទសវត្សមុននេះ ពេលដែលប្រាក់ដុល្លារពុំទាន់ហូរចូលពេញស្រុកខ្មែរនៅឡើយ កាលណាគេត្រូវទិញឬលក់អ្វីមួយធំដុំ មានដីធ្លី ផ្ទះសម្បែង ម៉ូតូ ឡានជាដើម គេទូទាត់ជាមាស។ ដូច្នេះហើយ អ្នកស្រែចម្ការតែងបេះពីមាត់ពង្រាត់ពីកដើម្បីផ្ញៀតទិញអលង្ការមានចិញ្ចៀន ខ្សែក ក្រវិលទុកសម្រាប់ពាក់លម្អ តែគោលបំណងធំនៅពីក្រោយ គឺសម្រាប់ទុកចាយទៅវិញពេលមានការចាំបាច់ បើតិចតួចគេអាចកាត់តែមួយផ្នែក។ ហេតុការណ៍នេះ ប្រហែលគ្រួសារខ្មែរណាក៏ធ្លាប់ឆ្លងកាត់ក្នុងមួយធាកជីវិតដែរ។ ដូច្នេះការវិនិយោគនៃគ្រួសារខ្មែរពីមុនមកអាចពោលសង្ខេបមកត្រឹមការប្រមូលសន្សំទ្រព្យធនជាវត្ថុមានតម្លៃ ត្បិតវត្ថុទាំងនោះគេអាចដោះដូរតាមក្រោយបានស្រួល។ នៅសម័យបុរាណ យើងឃើញគ្រួសារនីមួយៗសន្សំរក្សារហូតដល់គ្រឿងប្រាក់និងសំពត់ប្រណីតមានតម្លៃដូចជាហូលផាមួងជាដើម។ ជាទូទៅ គ្រួសារនីមួយៗតែងមានគ្រឿងប្រាក់ខ្លះដូចជាផ្តិល ជើងពាន ថាស ទៀប ឬហិបរក្សាទុកតាមផ្ទះរៀងៗខ្លួន។ គ្រឿងទាំងនោះគេប្រើប្រាស់ម្តងម្កាលក្នុងឱកាសបុណ្យទានឬមានភ្ញៀវពន្ធឺមានមុខមាត់ គេយកចេញមកប្រើ តែស្ទើរពេញមួយឆ្នាំ គ្រឿងប្រាក់នោះ គេរក្សាទុកយ៉ាងផ្ចិតផ្ចង់ ឬចាក់សោរទុកកំបាំងភ្នែកមនុស្សទូទៅផង។ គេប្រើវត្ថុដែលមានតម្លៃជាបន្ទាប់មានផ្តិលខាត់ ដែលធ្វើពីស្ពាន់ ជើងពាន ឬទៀបដែលត្បាញពីរពាក់ ឬធ្វើពីឈើខ្នុកម្រ័ក្សណ៍ជាដើម ដែលគេប្រើជាទូទៅ។

បើយើងពិនិត្យមើលសិលាចារឹកសម័យបុរាណវិញ យើងមានពត៌មានច្រើនដែលនិយាយពីការទិញលក់ដីស្រែ ឬលោះនិងទិញខ្ញុំ ដោយគិតតម្លៃជារបស់មានតម្លៃដូចជាគ្រឿងមាស គ្រឿងប្រាក់ ស្ពាន់ និងសត្វពាហនៈជាដើម។ ក្រៅពីសម្រាប់ជាគ្រឿងដោះដូរទំនិញ សិលាចារឹកទាំងនោះក៏លើកនិយាយពីតង្វាយទុកជាទ្រព្យនៃប្រាសាទនីមួយៗ ជាគ្រឿងមាស ប្រាក់ សំរឹទ្ធិ ស្ពាន់។ល។ ប្រាក់ដែលមានតម្លៃជាគ្រឿងទូទាត់ទំនិញធំៗដែលឃើញមាននិយាយក្នុងសិលាចារឹកទាំងនោះ គេប្រើប្រាស់តាមរូបភាពពីរ។ ទីមួយ គេគិតជាសាច់ប្រាក់តែម្តង បានសេចក្តីថាប្រាក់នោះមិនមែនជាគ្រឿង តែជាលោហៈមួយដុំដែលមានទម្ងន់ផ្សេងៗ។ គេគិតតម្លៃដីស្រែមួយ ឬខ្ញុំម្នាក់ជាវត្ថុផ្សេងៗ ខ្លះបូកផ្សំនឹងមាសឬ



ប្រាក់តាមទម្ងន់ណាមួយជាក់លាក់។ ការប្រើប្រាស់ប្រភេទទីពីរ គឺដូចដែលយើងតែងឃើញជាទូទៅ ហើយដែលយើងបាននិយាយច្រើនមកហើយ គឺការដោះដូរជាគ្រឿងប្រាក់ទៅនឹងទំនិញអ្វីមួយជារឿងធំដុំ។ សិលាចារឹកច្រើនមាននិយាយពីការដោះដូររបៀបនេះ ហើយដែលអ្នកប្រវត្តិសាស្ត្រអះអាងជាទូទៅថាជាប្រព័ន្ធពាណិជ្ជកម្មខ្មែរបុរាណរហូតដល់សតវត្សទី១៦ ពេលដែលមានការបោះពុម្ពប្រាក់កាក់ដំបូងៗក្នុងប្រវត្តិសាស្ត្រខ្មែរ។ ក៏ប៉ុន្តែការប្រើប្រាស់ប្រាក់ជាគ្រឿងសម្រាប់ដោះដូរក៏នៅតែបន្ត។ ប្រាក់កាក់សម្រាប់ចាយក៏ហាក់ដូចជាមិនទូលំទូលាយដែរ ទម្លាប់វិនិយោគលើវត្ថុមានតម្លៃមកទុកជាទ្រព្យចាំបាច់តាមគ្រួសារខ្មែរនៅបន្តរហូតដល់បច្ចុប្បន្ន។ ប្រព័ន្ធដោះដូរទំនិញធំៗជាមួយគ្រឿងមានតម្លៃនៅតែខ្លាំងក្លាហើយជាការនិយមផង។ យើងសង្កេតឃើញថាមកដល់សព្វថ្ងៃ ខ្មែរជាពិសេសអ្នកស្រែពុំមានទម្លាប់ទុកដាក់លុយនៅផ្ទះទេ។ លុយកាក់ដែលគេបានពីលក់ស្រូវអង្ករ គេទិញជាគ្រឿងមាសប្រាក់។ ដូច្នេះមកដល់ប្រមាណបីទសវត្សមុននេះ គ្រឿងប្រាក់គឺជាវត្ថុមួយដែលមានតម្លៃជាចលនទ្រព្យមួយយ៉ាងសំខាន់។

បើពោលឲ្យសង្ខេប យើងឃើញថាគ្រឿងប្រាក់មានទំនាក់ទំនងជាមួយការរស់នៅប្រចាំថ្ងៃរបស់ខ្មែរតាមលក្ខណៈផ្សេងៗគ្នា។ ចំណុចទីមួយដោយសារប្រាក់មានតម្លៃនិងគុណភាពពិសេសតែម្តង។ ចំណុចទីពីរ គឺសិល្បៈនៃការធ្វើគ្រឿងពីប្រាក់។ គ្រឿងប្រាក់ផលិតឡើងដោយមានក្បាច់ក្បូរយ៉ាងពិចិត្រ។ ចំណុចទាំងពីរនេះ ធ្វើឲ្យគឿងប្រាក់មានតម្លៃជាវត្ថុសម្រាប់ការដោះដូរក្នុងជំនួញជួញប្រែ មកដល់ពេលថ្មីៗនេះ ទោះបីជាមានធនាគារក្តី។ ចាប់តាំងពីពេលដែលប្រាក់ដុល្លារចរាចរក្នុងប្រទេសកម្ពុជា ហើយដែលអាចប្រើប្រាស់បានគ្រប់ឱកាសផង ពេលនោះតម្លៃនៃការប្រើប្រាស់គ្រឿងមាសប្រាក់ និងវត្ថុមានតម្លៃសម្រាប់ការដោះដូរឬទូទាត់ក្នុងការទិញដូរទំនិញធំៗដូចមុនលែងមានតទៅទៀតហើយ។ នេះជារឿងធម្មតាត្បិតប្រទេសមួយមិនអាចរស់នៅតាមប្រព័ន្ធសេដ្ឋកិច្ចដោះដូរគ្នាដូច្នេះបានទេ។ តែជាអកុសល ការវិវឌ្ឍន៍ខ្លះជះឥទ្ធិពលអវិជ្ជមានដល់វិស័យមួយទៀត ដូចជាតួនាទីសង្គមនៃគ្រឿងប្រាក់សព្វថ្ងៃក៏លែងមានដូចមុនទៀត រីឯអាជីពធ្វើគ្រឿងប្រាក់ក៏រួមថយមកត្រឹមបម្រើទីផ្សារទេសចរ ត្បិតទីផ្សារក្នុងស្រុកលែងមានតទៅទៀត។

### ៤. ប្រាក់និងព្រះមហាក្សត្រ

ក្នុងផ្នែកនោះ យើងនឹងពិនិត្យអំពីការផលិតនិងការប្រើប្រាស់គ្រឿងប្រាក់ក្នុងមជ្ឈដ្ឋានព្រះរាជវាំង។ យើងបានរៀបរាប់ពីខាងលើមកហើយថា អ្នកស្រុកជាទូទៅទុកគ្រឿងប្រាក់ជាទ្រព្យធនក្នុងគ្រួសារជាជាងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ គ្រឿងប្រាក់ទាំងនោះ គេរក្សាទុកដាក់យ៉ាងគត់មត់ណាស់ ស្ទើរតែមិនដែលយកមកប្រើប្រាស់ផង។ នេះជាការធម្មតាទេ ត្បិតប្រាក់ជាលោហធាតុកម្រ និងមានតម្លៃបន្ទាប់ពីមាស ចំណែកឯគ្រឿងប្រាក់តែម្តង គេចាត់ទុកជាវត្ថុពិចិត្រ។ ដូច្នេះអ្នកដែលមានលទ្ធភាពប្រើប្រាស់គ្រឿងប្រាក់ជាវត្ថុប្រើប្រចាំថ្ងៃបានលុះត្រាតែជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងច្រើនតែក្នុងចំណោមមនុស្សដែលមានការអប់រំខ្ពង់ខ្ពស់ផង។ បើពោលឲ្យខ្លី គឺសង្គមអភិជន ដែលក្នុងនោះរួមមានព្រះមហាក្សត្រនិងញាតិវង្ស បន្ទាប់មកជាមន្ត្រីធំៗ។ រហូតដល់បច្ចុប្បន្ន វាំងនៅតែជាមជ្ឈដ្ឋានដែលត្រូវការគ្រឿងប្រាក់ច្រើនជាងគេ។ ក្រៅពីជាគ្រឿងតម្កើងយសសក្តិផ្ទាល់ខ្លួនព្រះរាជាខ្មែរពេញព្រះទ័យប្រទានគ្រឿងប្រាក់ជារង្វាន់ដល់មន្ត្រីតូចធំ និងថ្នាក់ដឹកនាំនៃប្រទេសផ្សេងៗ (រូបលេខ៧៦)។



រូបលេខ៧៦៖ សម្តេចព្រះនរោត្តម សីហនុ និងព្រះអគ្គមហេសីប្រទានគ្រឿងប្រាក់ដល់ភ្ញៀវបរទេស។



សម័យបុរាណ អភិជនធំៗតែងមានជាងប្រាក់ផ្ទាល់ខ្លួន ឬជួលជាងមកធ្វើការក្នុងគេហដ្ឋានរបស់ខ្លួនកាលណាគេចង់ធ្វើគ្រឿងមាសប្រាក់និងអលង្ការសម្រាប់ប្រើប្រាស់ ឬទុកជាគ្រឿងសួយដល់ស្តេចឬមន្ត្រីធំៗផង។ ក្នុងវាំង ព្រះរាជាតែងមានជាងមួយក្រុមរ៉ាប់រងធ្វើកិច្ចការអ្វីៗសម្រាប់វាំង មានដូចជាជាងសាងសង់ ជាងគំនូរ ជាងធ្វើអលង្ការ និងជាងប្រាក់ជាដើម។ ជាងប្រាក់ធ្វើវត្ថុផ្សេងៗពីមាសនិងប្រាក់សម្រាប់ប្រើប្រាស់ក្នុងព្រះរាជវាំង គ្រឿងតង្វាយ និងវត្ថុប្រើក្នុងកិច្ចពិធី ព្រះបដិមាផ្សេងៗ និងគ្រឿងឥស្សរិយយស។ តឹកតាងផ្សេងៗ មានដូចជាផ្ទាំងចម្លាក់តាមប្រាសាទ សិលាចារឹក កំណត់ហេតុនៃជនបរទេសដែលមកដល់ស្រុកខ្មែរ និងបុរាណវត្ថុមួយចំនួនដែលមាននៅក្នុងវាំងសព្វថ្ងៃ បង្ហាញថាព្រះមហាក្សត្រខ្មែរសព្វព្រះទ័យយ៉ាងខ្លាំងទៅលើវត្ថុប្រណីតធ្វើពីមាសនិងប្រាក់។ ការរៀបរាប់របស់លោកជីវ តាក្វាន់ ក៏ល្មមឲ្យយើងយល់ស្របដូច្នេះបាន។ លោកបានរៀបរាប់ថា៖

> « ...គ្រួសារមន្ត្រីនិងអភិជនប្រើរបស់ធ្វើពីប្រាក់ ក្នុងវាំងគេប្រើប្រាស់របស់ដូចគ្នា តែធ្វើពីមាស។ ...នៅពេលព្រះរាជាយាងចេញពីវាំងម្តងៗ គេឃើញមានស្រីស្នំកាន់ពានមាសនិងប្រាក់ដែលមានក្បាច់រចនាយ៉ាងពិចិត្រ...»[៥៨]

ទំនៀមទម្លាប់នេះមានតរៀងមករហូតដល់សម័យបច្ចុប្បន្ន។ ពួកអឺរុបដែលមកដល់ប្រទេសកម្ពុជាកាលពីចុងសតវត្សទី១៩ បាននិយាយថា គេឃើញមហាក្សត្រខ្មែរតែងប្រទានរង្វាន់ជាគ្រឿងមាស និងប្រាក់ដល់មន្ត្រី អ្នកមុខអ្នកការដែលមានគុណបំណាច់ចំពោះរាជការ។ ជនបរទេសដែលចូលគាល់ព្រះអង្គ គឺព្រះអង្គតែងផ្តល់កិត្តិយសដោយប្រទានវត្ថុធ្វើពីប្រាក់ ជាពិសេសគ្រឿងប្រអប់ម្លូស្លាជាដើម[៥៩]។ ព្រះមហាក្សត្រក្រោយមកតែងបន្តទំនៀមនេះ។ យើងឃើញថា

---

៥៨ *Zhou 1993, p. 72.*

៥៩ *Vincent 1873, p. 295.*

ព្រះមហាក្សត្រខ្មែរនិយមប្រទានគ្រឿងប្រាក់ដល់ភ្ញៀវជាប្រមុខរដ្ឋផ្សេងៗដែលមកទស្សនាកម្ពុជា។ បើពិនិត្យរូបលេខ៧៧ យើងឃើញព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បង្ហាញគ្រឿងប្រាក់ចំពោះលោកជំទាវ *Jacqueline Kennedy* ភរិយាអតីតប្រធានាធិបតីនៃសហរដ្ឋអាមេរិក ដែលមកទស្សនាកម្ពុជានៅឆ្នាំ១៩៦៧ នូវគ្រឿងមាសប្រាក់ប្រណីតៗជាច្រើន ដែលព្រះអង្គនឹងប្រទានទៅលោកជំទាវ។



*រូបលេខ៧៧៖ សម្ដេចព្រះនរោត្តម សីហនុ ទតគ្រឿងប្រាក់ជាមួយលោកជំទាវ Jacqueline Kennedy។ គ្រឿងប្រាក់ទាំងនេះ ក្រោយមកព្រះអង្គប្រទានទៅលោកជំទាវជាវត្ថុអនុស្សាវរីយ៍។*

### ព្រះវិហារព្រះកែវមរកត

ប្រាក់ដែលជិតជាប់ក្នុងជីវភាពព្រះមហាក្សត្រនិងរាជវង្សខ្មែរ បង្ហាញកាន់តែច្បាស់តាមរយៈការរៀបចំសាងសង់និងការតុបតែងខាងក្នុងព្រះវិហារព្រះកែវមរកត ដែលជាវត្តសម្រាប់ហ្លួង និងព្រះញាតិវង្សធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា។ វត្តនេះរៀបចំចាត់ចែងសាងឡើងដោយព្រះបាទនរោត្តម នៅឆ្នាំ១៨៩២-១៩០២ ដោយក្រាលកម្រាលធ្វើពីប្រាក់សុទ្ធចំនួន៥៣២៩ដុំ ដែលឥដ្ឋមួយដុំៗទម្ងន់១,១២៥គ.ក្រ.[៦០]។ វត្តនេះជាចំណែកនៃព្រះបរមរាជវាំង ដែលសព្វថ្ងៃក្លាយជាមណ្ឌលទេសចរណ៍ដ៏ល្បីល្បាញនៃរាជធានីភ្នំពេញ។ ដោយសារកម្រាលប្រាក់ដែលក្រាលក្នុងព្រះវិហារនេះ ទើបទេសចរបស្ចិមប្រទេសហៅថា *"Silver pagoda"* ជាភាសាអង់គ្លេស ឬ *"Pagode d'Argent"* ជាភាសាបារាំង។ កម្រាលប្រាក់នេះក្រាលនៅឆ្នាំ១៩០៣ ហើយជួសជុលម្ដងទៀតនៅឆ្នាំ១៩៦២។

---

៦០ *Jeldres* និង *Chaijitvanit 1999, p. 34*។



ជំពូកទី៣

# ជាងសម័យបច្ចុប្បន្ន



ជាងប្រាក់មានន័យថាជាងដែលធ្វើគ្រឿងផ្សេងៗពីប្រាក់។ តែជាក់ស្តែង “ជាងប្រាក់” ធ្វើវត្ថុពីប្រាក់ ស្ពាន់ ទង់ដែង ជូនកាលរហូតដល់វត្ថុពីមាសផង។

បច្ចុប្បន្នជាងប្រាក់នៅស្រុកខ្មែរមានពីរប្រភេទធំៗ គឺជាងនៅតាមភូមិស្រុក និងជាងដែលបានរៀនសូត្រពីសាលារចនា។ ជាងក្រុមទីមួយចេះវិជ្ជាធ្វើប្រាក់តៗគ្នាពីជំនាន់មួយទៅជំនាន់មួយ រីឯការផ្ទេរចំណេះដឹងធ្វើឡើងក្នុងរង្វង់គ្រួសារឬសហគមន៍ប៉ុណ្ណោះ។ យើងសង្កេតឃើញថាក្រុមទីមួយនេះមាននៅតាមភូមិស្រុកមួយចំនួនក្នុងស្រុកខ្មែរ។ ភូមិស្រុកខ្លះមានការប្រមូលផ្តុំគ្នាជាសារជីវកម្មធ្វើប្រាក់ដាច់មុខ ដូចជាភូមិខ្លះនៅកំពង់ហ្លួង និងនៅកោះចិន។ ក្រុមទីពីរ ជាជាងដែលបានរៀនសូត្រពីសាលារចនា និងជាងចាស់ៗដែលប្រហែលផ្លាស់ទីមកកាន់ភ្នំពេញពេលដែលវាំងលើកមកទីនេះ។ សាលារចនា ក្រោយមកពង្រីកទៅជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅឆ្នាំ១៩៦៥ ពីមុនជាផ្នែកមួយនៃរោងជាងរបស់ព្រះរាជវាំង ដែលជាទីផលិតវត្ថុផ្សេងៗសម្រាប់តម្រូវការក្នុងវាំង និងហ្វឹកហ្វឺនជាងថ្មីៗ។ ក្រៅពីនេះយើងធ្លាប់ឮថាមានជាងខ្លះៗនៅបាត់ដំបងដែលធ្លាប់ធ្វើការឲ្យលោកម្ចាស់នាសម័យមុន។ សព្វថ្ងៃមានជាងខ្លះផ្លាស់ទីទៅខេត្តសៀមរាប ដោយសារខេត្តនេះក្លាយជាតំបន់ទេសចរណ៍ធំមួយនៃអាស៊ីអាគ្នេយ៍។

លោក *George Groslier* មានបេសកកម្មធំធេងមួយដើម្បីរៀបចំសាលារចនា។ ក្នុងការកិច្ចនេះលោកបានសិក្សាស៊ីជម្រៅអំពីជាងខ្មែរ ហើយបែងចែកជាពីរប្រភេទផ្សេងគ្នា ពោលគឺជាងក្រុម “ក” ដែលជាជាងទូទៅចេះតៗគ្នា និងជាងក្រុម “ខ” ដែលបណ្តុះបណ្តាលពីសាលារចនា។ គាត់ក៏បន្ថែមប្រភេទជាងក្រុមទីបី គឺក្រុម “គ” ដែលទទួលការបណ្តុះបណ្តាលបន្តពីជាងក្រុម “ខ”។ ការផ្ទេរចំណេះដឹងនៃប្រភេទជាងទាំងពីរក្រុមនេះធ្វើឡើងក្នុងសភាពផ្សេងៗ តាមការផ្សព្វផ្សាយអត្ថបទជាបន្តបន្ទាប់ក្នុងទស្សនាវដ្តីឥណ្ឌូចិននិងកម្រងសិក្សាមួយដាក់ឈ្មោះថា “សិល្បៈនិងបុរាណវិទ្យាខ្មែរ” ក្នុងចន្លោះឆ្នាំ១៩១៨-១៩៣០[៦១]

៦១ *Revue Indochinoise (1918-1919); Arts et Archéologie Khmère (1926); Revue des Arts Asiatiques, Vol.VI, 1929-30;* និងក្នុងទស្សនាវដ្តីមួយចំនួនទៀតដែលយើងមិនអាចយកមករៀបរាប់អស់ក្នុងទីនេះ។



ឃើញថាគាត់បានសិក្សាពិនិត្យប្រៀបធៀបយ៉ាងល្អិតពីកម្រិតទឹកដៃ និងខ្នាតនៃក្បូរក្បាច់រចនានៃវត្ថុដែលធ្វើដោយជាងទាំងពីរប្រភេទនេះ។ ក្រោយមកនៅឆ្នាំ២០០១អ្នកស្រី *Ingrid Muan* (ដែលទើបចាកលោកនេះទៅ) បានសិក្សាពីចិត្តសាស្ត្រនិងបញ្ហាស្តារសិល្បៈខ្មែរយ៉ាងពិស្តារក្នុងក្របខ័ណ្ឌនិក្ខេបបទបណ្ឌិតនៃសាកលវិទ្យាល័យ Columbia (សហរដ្ឋអាមេរិក)[៦២]។

## ១. ជាងប្រាក់នៅស្រុកខ្មែរ

លោក *George Groslier* ដែលទទួលរ៉ាប់រងរៀបចំសាលារចនាបានប្រមែប្រមូលជាងចាស់ៗពីតាមខេត្តខ័ណ្ឌនៃប្រទេសកម្ពុជាមកបង្រៀននៅសាលានេះ។ សិស្សដែលបញ្ចប់ការសិក្សាខ្លះត្រឡប់ទៅខេត្តខ្លួនវិញប្រកបរបរជាងប្រាក់និងបណ្តុះបណ្តាលកូនជាងជាបន្តបន្ទាប់។ ជាងខ្លះរកការងារនៅភ្នំពេញតាមហាងប្រាក់ធំៗ ឬធ្វើខ្លួនឯង។ សាលារចនាក៏បើកសារជីវកម្មផ្ទាល់ខ្លួនមួយសម្រាប់លក់គ្រឿងប្រាក់និងវត្ថុសិល្បៈដែលជាស្នាដៃសិស្សនៃសាលានេះ។ ខុសពីជាងនៅតាមស្រុកស្រែជនបទ ជាងដែលទទួលការបណ្តុះបណ្តាលពីសាលាធ្វើវត្ថុប្រណីតតាមក្បួនខ្នាត និងច្រើនរចនាក្បាច់ពិសេសៗ ដូចជាភ្ញីភ្ញើង ភ្ញីទេស ឬក្បាច់អង្គរជាដើម។ ជាងនៅកំពង់ហ្លួងកម្រធ្វើក្បាច់ដូចជាងនៅភ្នំពេញណាស់។ គេច្នាក់ក្បាច់តែមួយមុខឬពីរមុខប៉ុណ្ណោះ ហើយជាក្បាច់ងាយៗដូចជាក្បាច់ភ្ញីទេសនិងភ្ញីភ្ញើង។ ក្បាច់ភ្ញីទេសនោះក៏មិនសូវរស់រវើក ហើយដែលជាងនៃសាលារចនាហៅថាក្បាច់រយ ឬក្បាច់រាក់រយ[៦៣]។ ក្រៅពីធ្វើគ្រឿងសព្វសារពើ ជាងនៅភ្នំពេញច្រើនធ្វើព្រះពុទ្ធរូប ដែលជាងនៅកំពង់ហ្លួង-កោះចិនមិនហ៊ានធ្វើ។ ឯការដែលមិនហ៊ានធ្វើនេះមានមូលហេតុច្រើន ទីមួយពិបាក និងត្រូវមានខ្នាតត្រឹមត្រូវ ព្រមទាំងត្រូវមានក្បូរក្បាច់ច្រើន។ ទីពីរ ពាក់ព័ន្ធនឹងជំនឿ។ ជាងទាំងនោះពោលថា

៦២ *Muan, Ingrid, 2001,* Citing Angkor: The "Cambodian Arts" in the Ages of Restoration 1918-2000.

៦៣ បទសម្ភាសន៍ជាមួយលោកគ្រូ ជេត ចន គ្រូចូលនិវត្តន៍ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឯកទេសគំនូរបុរាណ។

ជារឿងមិនល្អសម្រាប់ខ្លួនដែលផុតជិរូបព្រះ ហើយពោលថាមានបាបខ្លាំងណាស់ ឬបណ្តាលឲ្យគេធ្លាក់ខ្លួនឈឺផង[៦៤]។

## តំបន់កំពង់ហ្លួង-កោះចិន

នៅមិនឆ្ងាយពីអតីតរាជធានីឧត្តុង្គ យើងឃើញភូមិផលិតគ្រឿងប្រាក់មួយចំនួន គឺភូមិពោធិតូច (ឃុំកំពង់ហ្លួង) និងនៅត្រើយខាងកើតមានភូមិព្រែកក្តាម (ឃុំកោះចិន) ជាដើម។ មុននឹងនិយាយអំពីជាងនៅតំបន់នេះ យើងសូមពិចារណាបន្តិចពីភូមិសាស្ត្រនេះ។ ឧត្តុង្គជាអតីតរាជធានីតាំងពីរវាងដើមសតវត្សទី១៧ មកដល់ចុងសតវត្សទី១៩ មុនពេលដែលព្រះករុណាព្រះនរោត្តមប្តូររាជធានីមកភ្នំពេញ។ ក្រៅពីសំណង់ប្រវត្តិសាស្ត្រសំខាន់ៗនៅលើកំពូលភ្នំអដ្ឋរស្ស (រូបលេខ៧៨) យើងឃើញមានវត្តចាស់ៗមួយចំនួននិងសំណល់ពុម្ពដែលគេបោះប្រាក់កាក់សម្រាប់ចាយក្នុងរាជ្យព្រះករុណាព្រះអង្គឌួង។ ភូមិស្រុកមួយចំនួននៅជុំវិញអតីតរាជធានីឧត្តុង្គនៅតែមានជំនាញធ្វើជាងរហូតដល់សព្វថ្ងៃ។ នៅឧត្តុង្គសម្បូណ៌ដោយជាងឈើដែលល្បីៗ។ ចំណែកភូមិផ្សារដែកមានជំនាញខាងស្មិតដ៏ល្បីល្បាញ ហើយនៅបន្តសិតព្រះពុទ្ធរូបឬបដិមាផ្សេងៗដល់សព្វថ្ងៃ។ រូបព្រះអង្គឌួង



រូបលេខ៧៨៖ ភ្នំអដ្ឋរស្សមើលពីកំពង់ហ្លួង។

---
៦៤ បទសម្ភាសន៍ជាមួយជាងសរ នៅភូមិពោធិតូច។



គង់លើសេះ ដែលតម្កល់ត្រង់ផ្លូវបំបែកចូលកំពង់ហ្លួងសិតដោយជាងមកពីភូមិផ្សារដែក (រូបលេខ៧៩)។ មនុស្សនៅត្រើយខាងលិចនិងត្រើយខាងកើតតំបន់កំពង់ហ្លួងដែលចេះផលិតគ្រឿងប្រាក់យ៉ាងចំណាននោះ គ្មានអ្វីធ្វើឲ្យយើងឆ្ងល់ទេ ត្បិតដែលហៅថា “រាជធានី” ពីមុនមកគឺតែងមានវាំងជាមណ្ឌល និងស្រុកមួយចំនួនជាចំណុះ។ វាំងតំណាងឲ្យនគរទាំងមូល ដូច្នេះហើយបានជានៅវាំងតែងមានរោងជាងសព្វបែបយ៉ាងបីដូចនគរមួយដែលត្រូវមានរោងជាងទាំងនោះសព្វទិសទីដែរ។ ជាងទាំងនោះផលិតរបស់របរដើម្បីតម្រូវការក្នុងវាំងផងនិងអ្នកក្រុងផង។ បើវាំងប្តូរទៅទីណាហើយ ព្រះរាជាតែងរៀបចំបង្កើតភូមិស្រុករបៀបនេះឡើងវិញនៅទីតាំងរាជធានីថ្មី ដោយនាំជាងទាំងគ្រួសារទៅជាមួយផងក៏សឹងមាន។



រូបលេខ៧៩៖ រូបព្រះអង្គឌួង សិតពីស្ពាន់ដោយជាងនៅភូមិផ្សារដែក។

## ជាងនៅកំពង់ហ្លួង

កំពង់ហ្លួងជាឃុំនៅក្នុងស្រុកពញាឮ ខេត្តកណ្តាល ដែលស្ថិតនៅចម្ងាយប្រមាណ៤០គ.ម.ខាងជើងភ្នំពេញ។ កំពង់ហ្លួងមាន៨ភូមិ ដែលក្នុងនោះភូមិពោធិតូចធ្វើគ្រឿងប្រាក់ ហើយក្លាយជារបរប្រចាំភូមិ។ រីឯភូមិសង្វរនៅសល់តែ២ឬ៣គ្រួសារប៉ុណ្ណោះ។ ភូមិពោធិតូចនៅធ្វើប្រាក់ស្ទើរគ្រប់ផ្ទះ។ ភូមិពោធិតូចដែលជាប្រជុំជននៃឃុំនេះ ស្ថិតនៅចំទីតាំងអតីតផែរាជធានីតែម្តង។ ហេតុដូច្នេះបានជាអ្នកស្រុកហៅខ្លួនឯងភ្ជាប់នឹងឈ្មោះឃុំតែម្តង ពោលគឺអ្នកកំពង់ហ្លួង។ កំពង់ហ្លួងមានន័យថាជាផែព្រះរាជា ពោលគឺផែនៃរាជធានី។ ផែនេះមាននាវាតូចធំគ្រប់បែបយ៉ាងចូលចតពេលដែលឧត្តុង្គនៅជារាជធានី ក្នុងនោះមាននាវាពួកប៉័ទុយហ្គេអេស្ប៉ាញ៉ុល ជប៉ុន និងចុងក្រោយគឺនាវាបារាំង។

ជាងប្រាក់នៅភូមិពោធិតូច មានទំនៀមផលិតគ្រឿងប្រាក់យ៉ាងពិសេសមួយ គឺគេធ្វើប្រអប់ប្រាក់ដែលមានរូបជាសត្វ និងផ្លែឈើ (រូបលេខ ៨០)។ល។ គេកម្រផលិតរបស់ផ្សេងពីនេះណាស់ពីមុនមក។ ការធ្វើវត្ថុទាំងនេះទាមទារជំនាញពិសេស ត្បិតជាវត្ថុតូចដែលត្រូវមានរាងរៅកាច់កេរ និងមានក្បូរក្បាច់ច្រើនផង។



រូបលេខ៨០៖ ឆ្លាក់គ្រឿងប្រាក់រូបដំរី នៅភូមិពោធិតូច។

## ជាងនៅកោះចិន

ភូមិនានានៅត្រើយខាងកើតនៃទន្លេសាបដែលនៅទល់មុខគ្នានឹងកំពង់ហ្លួងនោះរាប់បានថាជាចំណែកនៃអតីតរាជធានីឧត្តុង្គដែរ។ មូលហេតុដែលនាំឲ្យភូមិមួយនៅទីនេះមានជំនាញធ្វើគ្រឿងប្រាក់ គឺមិនខុសពីករណីនៅភូមិពោធិតូចឡើយ។ អ្វីដែលខុសគ្នានោះ គឺប្រភេទវត្ថុដែលគេធ្វើផ្សេងគ្នា។ រីឯជាងនៅព្រែកក្តាមកោះចិនធ្វើវត្ថុធំៗ និងរាងរៅត្រង់ៗ ដូចជាថាស តុ ចង់រង ផ្តិល ក្អម ជើងស្រាពក់ ជើងពាននិងគ្រឿងរណ្តាប់ក្នុងមង្គលការ (រូបលេខ៨១)។ល។ គ្រឿងទាំងនេះមើលទៅឃើញថាងាយធ្វើជាងប្រអប់រូបសត្វនិងផ្លែឈើដែលធ្វើនៅភូមិពោធិតូច។



រូបលេខ៨១៖
ឆ្លាក់ផ្តិលនិងជើងស្រាពក់
នៅភូមិកោះចិន។



## នៅភ្នំពេញ

ដូចបាននិយាយម្តងហើយថា ពេលរាជធានីប្តូរមកភ្នំពេញ យើងឃើញជាងចំណានៗមកជាមួយ ហើយរស់នៅមិនឆ្ងាយពីវាំងតាមបណ្តោយដងវិថីព្រះសុធារសត្រង់ទីតាំងដែលគេហៅថាផ្សារស៊ីញ៉ែក (រូបលេខ៨២)។ ក្រោយមកក្លាយជាភូមិលក់គ្រឿងប្រាក់ល្បីល្បាញនៃប្រទេសកម្ពុជានាទសវត្សរ៍១៩៥០ដល់១៩៧០។ ពេលដែលរាជធានីមកនៅភ្នំពេញ ជាងប្រាក់នៅកំពង់ហ្លួងក៏ក្លាយជាជាងខេត្ត ឬជាងជនបទ។



រូបលេខ៨២៖ ហាងលក់គ្រឿងប្រាក់នៅតាមបណ្តោយផ្លូវព្រះសុធារស។



រូបលេខ៨៣៖ លោកស៊ុម ស៊ីនឿន ជាងប្រាក់នៅភ្នំពេញ។

ក្រោយឆ្នាំ១៩៧៩ ជាងប្រាក់ដែលនៅសេសសល់ពីស្លាប់ ហើយធ្លាប់ប្រកបរបរនៅភ្នំពេញខ្លះត្រឡប់មកវិញប្រកបរបរធ្វើប្រាក់បន្ត។ ជាងមួយចំនួនជំចាស់ណាស់ទៅហើយ ហើយមិនអាចធ្វើការងារនេះតទៅទៀតបាន។ មួយវិញទៀតកម្រៃដែលបានមកមិនសមស្របនឹងការងារនិងពេលវេលា ខ្លះក៏បោះបង់របរនេះ។ ជាងដែលបណ្តុះបណ្តាលថ្មីក្រោយឆ្នាំ១៩៧៩ នៅសល់២ទៅ៣នាក់ប៉ុណ្ណោះដែលនៅបន្តធ្វើប្រាក់។ សព្វថ្ងៃជាងដែលគេស្គាល់ជាងគេ គឺលោកស៊ុម ស៊ីនឿន (រូបលេខ៨៣) ដែលទទួលការបណ្តុះបណ្តាលផ្ទាល់ពីឪពុកលោកដែលជាជាងមានឈ្មោះបោះសម្លេងតាំងពីមុនសង្គ្រាម និងគ្រូបង្រៀនខាងចម្លាក់ប្រាក់នៅសាលារចនាផង គឺលោកតាស៊ុម សាម៉ៃ។

### នៅសៀមរាប

ជាងនៅសៀមរាប ជាជាងដែលធ្វើចំណាកស្រុកពីតំបន់ផ្សេងៗ ជាពិសេសពីតំបន់កំពង់ហ្លួង-កោះចិនៗ របៀបផលិតពុំមានអ្វីខុសប្លែកពីតំបន់ទាំងនោះទេៗ អ្នកខ្លះទៅបើកហាងលក់គ្រឿងប្រាក់ និងមានរោងជាងផ្ទាល់ខ្លួនតាមគ្រួសារ (រូបលេខ៨៤)[៦៥]ៗ ការផលិតនេះក៏គ្រាន់តែជារបៀបបង្ហាញដើម្បីទាក់ទាញភ្ញៀវទេសចរប៉ុណ្ណោះៗ គ្រឿងប្រាក់ភាគច្រើនគេប្រមូលពីកំពង់ហ្លួង-កោះចិនៗ ជាងខ្លះទៅពីភូមិផ្សេងៗដែរៗ ជាងជុំ ថាវ ទៅពីភូមិកោះដាច់ ឃុំមុខកំពូល ខេត្តកណ្ដាលៗ ក្នុងរូបលេខ៨៤គឺជាងថាវធ្លាប់រៀនតពីគ្រូប៊ិន និងគ្រូសុវាល់ ខេម ដែលចេញពីសាលារចនាៗ គាត់ទៅធ្វើជាងឲ្យផ្ទះលក់គ្រឿងប្រាក់នៅសៀមរាបដោយទទួលជាប្រាក់ខែៗ ឯការងារគឺដើម្បីបង្ហាញភ្ញៀវ មិនមែនជាផលិតកម្មពេញលេញទេៗ

ដូច្នេះសរុបទៅ ទោះបីមានជាងបែកសាយភាយដល់សៀមរាបក្ដី តែក៏ពុំទាន់ជារបរដែលមានលំនឹងទៅអនាគតដែរៗ ឯគ្រឿងប្រាក់ដែលត្រូវផ្គត់ផ្គង់ទីផ្សារគឺយកទៅពីកំពង់ហ្លួង ឬកោះចិនដដែលៗ



រូបលេខ៨៤៖ ឆ្លាក់ប្រាក់នៅមុខហាងដើម្បីទាក់ទាញភ្ញៀវទេសចរនៅខេត្តសៀមរាបៗ

[៦៥] ឧទាហរណ៍ ហាងលក់ប្រាក់យីហោ សារី កល្យាណ នៅតាមបណ្ដោយវិថីហ្សង់ កូម៉ៃ ដែលម្ចាស់ឈ្មោះ សារី កល្យាណ ទៅពីភូមិព្រែកក្ដាម ឃុំកោះចិន ខេត្តកណ្ដាលៗ



## ២. ការបណ្ដុះបណ្ដាល និងផ្ទេរចំណេះដឹង

ជាទូទៅ ការបណ្ដុះបណ្ដាលនិងផ្ទេរចំណេះដឹងក្នុងវិស័យសិល្បៈនៅស្រុកខ្មែរផ្អែកតាមរបៀបបុរាណ ពោលគឺការផ្ទេរពីជំនាន់មួយទៅជំនាន់មួយក្នុងរង្វង់គ្រួសារ ឬសហគមន៍ៗ បើឪពុកជាជាងប្រាក់ ភាគច្រើនកូននឹងក្លាយជាជាងប្រាក់ទៅអនាគតៗ វត្តអារាមក៏មានតួនាទីសំខាន់ក្នុងការបណ្ដុះបណ្ដាលវិជ្ជាសព្វសារពើតាំងពីព្រះពុទ្ធសាសនា អក្សរសាស្ត្រ រហូតដល់ការងារជាងផងៗ ទំនៀមនេះមានឫសគល់តាំងពីសម័យបុរាណដែលអាស្រមនានាក៏មានតួនាទីជាកន្លែងបណ្ដុះបណ្ដាលវិជ្ជាផ្សេងៗៗ ប៉ុន្តែ តាមការសង្កេតរបស់លោក *George Groslier* គាត់មើលឃើញថា ការងារជាងដែលគេអាចរៀននៅតាមវត្តអារាម មានដូចជាជាងឈើ ជាងឆ្លាក់ ជាងខ្នុក ជាងគំនូរ រីឯជាងស្មិត ជាងអលង្ការ ជាងប្រាក់ ឬជាងស្ពូនច្រើនតែមាននៅក្រៅវត្តៗ ហេតុនេះហើយការងារជាងនៅស្រុកខ្មែរ ជាទូទៅមិនសូវរីកសាយភាយចេញពីរង្វង់ត្រកូលណាមួយណាស់ៗ ពូជពង្សណាមួយចេះការជាងអ្វីមួយហើយ គេក៏កម្រចែករំលែកទៅអ្នកក្រៅ បើពុំនោះទេអ្នកដែលមកសុំរៀននេះត្រូវនៅជាកូនជាងយ៉ាងយូរដោយពុំមានទទួលកម្រៃអ្វីផងៗ ណាមួយក្នុងផ្នត់គំនិតខ្មែរទូទៅ វិជ្ជាជាងផ្សេងៗតែងមានភ្ជាប់នឹងអាគម ឬត្រូវរៀបចំរណ្ដាប់ជាតង្វាយដល់គ្រូជា “អមនុស្ស” ដែលគេដឹងជាទូទៅថាជា “ព្រះពិស្ណុការ”ៗ

### ការផ្ទេរចំណេះនៅសាលារចនា

ពេលដែលអាណាព្យាបាលបារាំងចាប់ផ្ដើមនៅកម្ពុជា ធនធានមនុស្សហាក់ដូចជាចុះខ្សោយខ្លាំង ជាពិសេសសិល្បករ និងជាងចំណានៗៗ ជាងក្រុម “ក” នៅសេសសល់ខ្លះៗ ដើម្បីស្ដារប្រទេសឡើងវិញ អាណាព្យាបាលបារាំងត្រូវរើសរកអ្នកចេះខ្មែរមកធ្វើការៗ លោក *George Groslier* មាននាទីទទួលបន្ទុកស្ដារវិស័យសិល្បៈខ្មែរឡើងវិញកាលពីឆ្នាំ១៩១៨ៗ គាត់បានប្រមែប្រមូលគ្រូចាស់ៗដែលនៅរាយប៉ាយតាមខេត្ត និងនៅក្នុងភាំងដើម្បីជួយបណ្ដុះបណ្ដាលកូនខ្មែរឡើងវិញៗ គាត់ក៏រៀបចំពង្រីករោងជាងព្រះបរមជាងភាំងឲ្យទៅជាសាលារចនាៗ ផ្នែកចម្លាក់ប្រាក់ជាផ្នែកសំខាន់មួយនៃផ្នែកទាំង៦នៃសាលានេះៗ លោក *Groslier*

បានរៀបចំឲ្យមានការបង្រៀនមានក្បួនខ្នាតត្រឹមត្រូវ ម៉ឺងម៉ាត់ និងបម្រើដល់ចំណូលចិត្តទំនើបផង។ កម្មវិធីបណ្តុះបណ្តាលនេះ មានបង្ហាញក្នុងអត្ថបទរបស់គាត់ដែលមានចំណងជើងថា *La convalescence des Arts cambodgiens*។ កម្មវិធីបណ្តុះបណ្តាលមានជាបន្តបន្ទាប់រហូតសាលារចនាប្រែក្លាយជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅឆ្នាំ១៩៦៥ ដោយមាន៥មហាវិទ្យាល័យ គឺមហាវិទ្យាល័យស្ថាបត្យកម្ម មហាវិទ្យាល័យបុរាណវិទ្យា មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យនាដសាស្ត្រ និងមហាវិទ្យាល័យតូរ្យតន្ត្រី។ ផ្នែកផ្សេងៗក្នុងកម្មវិធីនៃសាលារចនាចាស់ពង្រីកទៅជាមហាវិទ្យាល័យសិល្បៈសូនរូប ហើយដែលកម្មវិធីបណ្តុះបណ្តាលចែកជាពីរទៀត គឺថ្នាក់មធ្យម និងថ្នាក់ឧត្តម។ ផ្នែកចម្លាក់ប្រាក់មានតែក្នុងកម្មវិធីថ្នាក់មធ្យមប៉ុណ្ណោះ។ ចាប់ពីពេលបើកសាលាដំបូងៗ គេឃើញសិស្សដែលចាប់យកមុខវិជ្ជាចម្លាក់ប្រាក់មានចំនួនកើនឡើងជាលំដាប់។ គ្រឿងប្រាក់ខ្មែរចាប់រីកចម្រើនឡើងល្បីល្បាញរហូតដល់កម្ពុជាធ្លាក់ចូលក្នុងរបបខ្មែរក្រហម។ ក្រោយ១៩៧៩ សាលារចនាបើកទ្វារដើម្បីបណ្តុះបណ្តាលជាង និងសិល្បករឡើងវិញ តែមិនមែនជាសាកលវិទ្យាល័យដូចមុនឆ្នាំ១៩៧៥ទេ ពោលគឺក្នុងទ្រង់ទ្រាយប្រហាក់ប្រហែលមុនឆ្នាំ១៩៦៥។ ផ្នែកចម្លាក់ក៏មានក្នុងកម្មវិធីនេះ ដើម្បីទទួលសិស្សឲ្យចូលរៀន តែមិនមានចំនួនច្រើន ហើយមិននិយមដូចមុនទេ។ សិស្សដែលបញ្ចប់ការសិក្សាទទួលបានសាលាកប័ត្រសិល្បៈភាគច្រើនមិនបានទៅប្រកបរបរជាងប្រាក់ ឬជួយបណ្តុះបណ្តាលបន្តដូចមុនទៀតទេ ក្នុងនោះមួយភាគធំនៅប្រកបរបរជាជាងគំនូរ ឬអ្នករដ្ឋបាល។ សព្វថ្ងៃ យើងសង្កេតឃើញថាផ្នែកចម្លាក់ស្ទើរតែពុំមានសិស្សចាប់យកឯកទេសនេះតទៅទៀតណាស់។

## ការផ្ទេរចំណេះក្នុងរង្វង់គ្រួសារ និងសហគមន៍

ការបណ្តុះបណ្តាលក្នុងរង្វង់គ្រួសារ និងសហគមន៍នៅខ្លាំងក្លានៅឡើយ។ នៅភូមិពោធិតូច និងកោះចិន យើងឃើញមានក្មេងៗចាប់ប្រកបរបរនេះជាបណ្តើរៗ។ ការបណ្តុះបណ្តាលនិងផ្ទេរចំណេះដឹងនេះធ្វើទៅដោយសន្សឹមៗ។ ក្មេងចេះធ្វើប្រាក់ដោយមិនដឹងខ្លួន ត្បិតពុំមានកម្មវិធី ឬមេរៀនដូចទៅសាលាឡើយ។



កូនចៅអ្នកស្រុកដែលមកសុំរៀនពីជាងធំនៅក្នុងភូមិ គេពុំតម្រូវឲ្យបង់ប្រាក់ទេ។ ក្មេងៗបង់ជាកម្លាំងជួយមេជាងទាំងនោះ ជាពិសេសពីមុនគេត្រូវការកម្លាំងពលកម្ម ដោយសារអ្វីៗសុទ្ធតែធ្វើដោយដៃ។ ទំនៀមនេះចេះតែបន្តមកឥតដាច់[៦៦]។ តែក៏មានសញ្ញាអវិជ្ជមានមួយចំនួនដែរ។ ជាងធំៗសព្វថ្ងៃត្អូញត្អែរពីកម្រៃដែលបានតិច មិនសមនឹងពលកម្ម។ ជាងដែលនៅធ្វើសព្វថ្ងៃដោយសារកម្លាំងចិត្តច្រើនជាង។ ជាងទាំងនោះចង់ឲ្យកូនចាប់យកវិជ្ជាផ្សេងវិញ។

## ជីវប្រវត្តិជាងប្រាក់ខ្លះៗ

ផ្នែកនេះ យើងនឹងរៀបរាប់ពីជាងប្រាក់ល្បីៗមួយចំនួន ពោលគឺយើងនឹងនិយាយខ្លះពីជីវប្រវត្តិជាងនិងប្រភេទគ្រឿងប្រាក់ដែលគាត់ផលិត។ ផ្នែកទាក់ទងអំពីជាងប្រាក់និងការផ្ទេរចំណេះដឹង យើងបានដឹងខ្លះៗរួចមកហើយថា គេអាចបែងចែកបានជាបីក្រុម។ ជាងក្រុមទី១ គឺជាងដែលទទួលការសិក្សាតាមក្បួនខ្នាត និងក្បាច់រចនាពីសាលារចនា (សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ)។ ជាងក្រុមទី២ គឺជាងដែលនៅតាមភូមិស្រុកមួយចំនួនដែលចេះតៗគ្នាពីឪពុកម្តាយ ឬចាស់ទុំនៅក្នុងសហគមន៍ជាមួយគ្នា។ ចំណែកឯជាងក្រុមទី៣ ជាជាងដែលរៀនបន្តពីជាងក្រុមទី១។ ខាងក្រោមនេះ យើងនឹងលើកយកជាងប្រាក់ខ្លះមកបង្ហាញ។ ជាងទាំងនេះមានប្រវត្តិក្នុងការចាប់ផ្តើមចំណេះវិជ្ជាផ្នែកជាងប្រាក់ផ្សេងៗពីគ្នា និងនៅទីកន្លែងផ្សេងពីគ្នា។

### លោកគ្រូ ស៊ុម សាម៉ៃ

លោកគ្រូកើតនៅភ្នំពេញ ឆ្នាំ១៩២៤ ដែលមានជីតានិងឪពុកជាជាងប្រាក់ពីមុនមកដែរ។ លោកតាចូលរៀនផ្នែកជាងប្រាក់នៅសាលារចនា ក្រុង

៦៦ ជាងធំៗដែលខ្ញុំបានជួបនិយាយថា មានក្មេងឬយុវជនច្រើនមករៀនធ្វើជាមួយគាត់ដោយគ្មានចំណាយលុយអ្វីទេ។ គាត់សប្បាយឲ្យតែមានយុវជនចង់ចេះ ត្បិតគាត់ចាស់ កម្លាំងខ្សោយផង (ជាងស ភូមិពោធិតូច)។

ភ្នំពេញនៅពេលលោកមានអាយុ១៥ឆ្នាំ ក្រោយមកក្លាយជាសាស្ត្រាចារ្យនៅសាលានេះផង ប្រកបរបរធ្វើប្រាក់នៅផ្ទះផង។ លោកតាធ្វើគ្រឿងប្រាក់សព្វបែបយ៉ាង គឺតាំងពីគ្រឿងអលង្ការមាសប្រាក់ គ្រឿងជំជុំ និងព្រះពុទ្ធរូបទៀតផង។ លោកតាស៊ិម សាម៉ៃ បានទទួលកិត្តិយសជាវរសិល្បករនៅឆ្នាំ១៩៩៣ ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងចូលនិវត្តន៍នៅឆ្នាំ១៩៩៧។ លោកតាឈប់ធ្វើប្រាក់ប្រហែលបីឆ្នាំមកហើយ ដោយសារវ័យកាន់តែជរាណាស់ទៅហើយ។ ក្នុងចំណោមកូនរបស់លោកតាទាំងអស់មានខ្លះចេះធ្វើប្រាក់ដែរ តែមានតែលោកស៊ិម ស៊ីនឿន ម្នាក់ប៉ុណ្ណោះដែលដើរតាមគន្លងរបស់គាត់។ គ្រឿងប្រាក់ដែលលោកតាបានធ្វើរហូតមកដល់សព្វថ្ងៃ ខ្លះមាននៅក្នុងវាំង ខ្លះនៅតាមគេហដ្ឋានមន្ត្រីធំ តាមស្ថានទូត និងខ្លះទៀតនៅបរទេស (រូបលេខ៨៥-៨៦)។



រូបលេខ៨៥៖ លោកគ្រូស៊ិម សាម៉ៃ។



រូបលេខ៨៦៖ គ្រឿងប្រាក់ធ្វើដោយលោកគ្រូ សាម៉ៃ។

## លោកស៊ិម ស៊ីនឿន

លោកស៊ិម ស៊ីនឿន ជាកូនលោកតាស៊ិម សាម៉ៃ។ សព្វថ្ងៃលោកស៊ីនឿនជាជាងប្រាក់ដែលមានឈ្មោះល្បីល្បាញ ហើយដែលគេស្គាល់ជាងគេ។ លោកស៊ីនឿនចូលសិក្សានៅសាលារចនាក្នុងវគ្គពិសេសក្រោយរបបខ្មែរក្រហមដួលរលំ និងទទួលបានសាលាកប័ត្រផ្នែកសិល្បៈ។ សព្វថ្ងៃលោកស៊ីនឿន ជាសាស្ត្រាចារ្យ



ផ្នែកចម្លាក់នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផង និងធ្វើប្រាក់ផ្ទាល់ខ្លួនផង។ ទន្ទឹមនឹងការបង្រៀននៅសាកលវិទ្យាល័យ គាត់មានកូនជាងជាច្រើនដែលមករៀននៅផ្ទះ ហើយដែលខ្លះចេញទៅប្រកបរបររៀងៗខ្លួន។ សព្វថ្ងៃលោកស៊ីនឿនធ្វើគ្រឿងប្រាក់ប្រណីតៗគ្រប់បែបយ៉ាង ហើយច្រើនតែម្ចាស់វត្ថុមករកឲ្យធ្វើផ្ទាល់សម្រាប់ប្រើប្រាស់ ឬសម្រាប់ជាវត្ថុជូនដល់អ្នកមុខអ្នកការ។ ជួនកាលគេមកធ្វើដើម្បីរក្សាទុកជាកេរ្តិ៍ដំណែលគ្រឿងប្រាក់ខ្មែរទៀតផង (រូបលេខ៨៧-៩០)។ លោកស៊ីនឿន ធ្វើគ្រឿងអលង្ការគ្រឿងប្រាក់ទូទៅ គ្រឿងបូជាមាន ព្រះពុទ្ធរូប ផ្កាប្រាក់ចេតិយ កោដ្ឋរហូតដល់មកុដ ក្បាំង និងគ្រឿងល្ខោនព្រះរាជទ្រព្យ។



រូបលេខ៨៧៖ លោកស៊ិម ស៊ីនឿន។



រូបលេខ៨៨



រូបលេខ៨៩



រូបលេខ៩០

រូបលេខ៨៨-៩០៖ ជាគ្រឿងប្រាក់ធ្វើដោយលោកស៊ិម ស៊ីនឿន។

## លោក សុខ ឡេង

លោកសុខ ឡេង (ហៅកុយ) ជាជាងប្រាក់នៅភូមិពោធិតូច។ សព្វថ្ងៃគាត់មានអាយុ៥២ឆ្នាំ មានប្រពន្ធដែលស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង។ លោកឡេងរៀនពីឪពុកតាំងពីនៅក្មេង ហើយបានបង្រៀនប្រពន្ធឲ្យចេះឆ្លាក់ប្រាក់យ៉ាងចំណានទៀតផង។ គ្រួសារនេះមានកូនពីរនាក់ តែពុំមានកូនណាមួយចង់ស្នងវិជ្ជានេះពីឪពុកម្ដាយសោះ។ ភាគច្រើនគាត់ទទួលធ្វើតែគ្រឿងប្រាក់ប៉ុណ្ណោះ។ គាត់ល្បីខាងឡើងក្បាលដែករូបសត្វ ឬផ្លែឈើបានគ្រប់បែបយ៉ាង។ ទេពកោសល្យពិសេសរបស់លោក គឺរូបសត្វដែលមានខ្នាតតូចខ្លាំង រូបសត្វធំៗ និងពូកែធ្វើពុម្ព។ សព្វថ្ងៃរូបសត្វដែលតូចខ្លាំងជាជំនាញផ្ដាច់មុខរបស់គាត់ ហើយដែលគាត់ធ្វើសម្រាប់បោះឲ្យម៉ូយនៅភ្នំពេញដោយខ្លួនឯងផ្ទាល់ (រូបលេខ៩១-៩៦)។



រូបលេខ៩១៖ លោកសុខ ឡេង។



រូបលេខ៩២



រូបលេខ៩៣



រូបលេខ៩៤



រូបលេខ៩៥



រូបលេខ៩៦

រូបលេខ៩២-៩៦៖ ជាគ្រឿងប្រាក់ធ្វើដោយលោកសុខ ឡេង។



## លោក ប៉ែន សរ

លោកប៉ែន សរ ជាជាងប្រាក់នៅក្នុងភូមិពោធិតូច។ ជាងសរមានជំនាញខាងឡើងក្បាលដែក (ឡើងរាង) រីឯប្រពន្ធជាអ្នកឆ្លាក់។ ជាងសរចាប់រៀនធ្វើប្រាក់ពីឆ្នាំ១៩៩៧ ពីឪពុកនិងជាងចាស់ៗនៅក្នុងភូមិជាមួយ។ ជាងសររៀបការជាមួយនាងខាន់ ស៊ីណាត ដែលជាអ្នកស្រុកពោធិតូចនេះតែម្ដង។ នាងស៊ីណាត ចេះឆ្លាក់ប្រាក់តាំងពីអាយុ១០ឆ្នាំម្ល៉េះ។ គ្រួសារជាងសរនិងនាងស៊ីណាតមានជំនាញពិសេសខាងធ្វើសត្វផ្សេងៗ និងមានកូនជាងជាសាច់ញាតិបួនប្រាំនាក់ទៀតមកនៅធ្វើជុំគ្នា។ ហេតុនេះហើយជាងសរអាចម៉ៅការងារធំៗពីម្ចាស់ហាងប្រាក់នៅភ្នំពេញ ឬឈ្មួញកណ្ដាលបាន។ ទន្ទឹមនឹងនេះ ប្រពន្ធគាត់ក៏ឆ្លៀតដាក់លក់នៅផ្ទះខ្លះផង។ សព្វថ្ងៃជាងសរបែកគំនិតធ្វើគ្រឿងស្ពាន់ជាផ្ទាំងចម្លាក់ធំៗ ដូចជាចម្លាក់ហោជាងភូមិគ្រឹះប្រណីតៗ ចង្កៀងព្យួរពិតានសណ្ឋាគារ និងសញ្ញានៃក្រុមហ៊ុនផ្សេងៗ។ រូបហង្សនៃធនាគារអេស៊ីលីដាច្រើនតែជាស្នាដៃរបស់គ្រួសារគាត់ (រូបលេខ៩៧-១០០)។



រូបលេខ៩៧



រូបលេខ៩៨



រូបលេខ៩៩



រូបលេខ១០០

រូបលេខ៩៧-១០០៖ ជាស្នាដៃរបស់ក្រុមគ្រួសារជាងសរ។

### លោក វ៉ា គឹមឡេង

លោកវ៉ា គឹមឡេង ជាជាងប្រាក់នៅភូមិកោះចិន។ សព្វថ្ងៃជាងឡេងមានអាយុ៧១ឆ្នាំ។ ប្រពន្ធរបស់គាត់គឺអ៊ំស្រី ខៀវ សុខុន (ហៅអ៊ំ ហឹន) ក៏ជាជាងធ្លាក់ៗ គាត់មានកូន៨នាក់ ប្រុស៥ ស្រី៣ ហើយចេះធ្វើប្រាក់ទាំងអស់គ្នា។ ពីមុនកូនទាំងអស់នៅជុំគ្នាធ្វើប្រាក់ជាមួយឪពុកម្តាយ។ សព្វថ្ងៃកូនៗគាត់មានគ្រួសារបែកផ្ទះរៀងៗខ្លួន តែនៅរួមគ្នាធ្វើប្រាក់ដដែល ដោយមានឪពុកម្តាយជាជំហរ។ ជាងឡេងចាប់ផ្តើមធ្វើប្រាក់តាំងពីក្មេង ហើយធ្លាប់បានចូលប្រលងស្នាដៃនៅភ្នំពេញដើម្បីបានប័ណ្ណទិញប្រាក់ពីសហករណ៍។ ជាងឡេងមានទឹកដៃល្អ ហើយឈ្មួញកណ្តាលមានទំនុកចិត្តផង។ គាត់អាចធ្វើគ្រឿងតុ ថាស ជើងស្រាពក់ ចង់រង ផ្តិល... ពោលគឺរាល់គ្រឿងដែលជាឯកទេសនៃភូមិកោះចិននេះធ្វើ។ សព្វថ្ងៃដោយសារមានកូនជាកម្លាំង ដូច្នេះជាងឡេងអាចទទួលការងារធំៗ និងបន្ទាន់ពីម៉ូយនៅភ្នំពេញបាន។ អ្នកលក់គ្រឿងប្រាក់នៅភ្នំពេញនរណាក៏ស្គាល់គាត់ដែរ។ ដោយកាន់តែចាស់ សព្វថ្ងៃជាងឡេង និងអ៊ំហឹនជាប្រពន្ធលែងធ្វើទៀតហើយ តែនៅជាជំហរទទួលពីម៉ូយនៅភ្នំពេញមកដាក់ឲ្យកូនៗគាត់ធ្វើ។ ម៉ូយនៅភ្នំពេញដែលយកប្រាក់មកដាក់ឲ្យជាងនៅទីនេះធ្វើ លុះត្រាតែគេទុកចិត្តណាស់ ហើយដឹងថាមានទឹកដៃល្អផង។ ជាងឡេងនិងកូនៗរបស់គាត់មានមោទនភាពនឹងមុខរបរជាជាងប្រាក់នេះណាស់ ហើយជឿជាក់ថាចម្លាក់ប្រាក់ខ្មែរនឹងមិនសាបសូន្យទេ។

## ៣. ផលិតកម្មនិងការបែងចែកតួនាទី

តាំងពីសម័យបុរាណដល់បច្ចុប្បន្ន គ្រឿងប្រាក់និងបច្ចេកទេសផលិតនៅកម្ពុជាក៏ដូចនៅអាស៊ីអាគ្នេយ៍ដែរ មានការប្រែប្រួលតិចតួចណាស់។ ឯការប្រែប្រួលនេះ កើតឡើងជាពិសេសពេលម៉ាស៊ីនខ្លះដែលអាចជំនួសដៃប៉ុណ្ណោះ បើជាលំនាំនៃការផលិតទូទៅគឺនៅដដែល។ មូលហេតុនេះប្រហែលមកពីលក្ខណៈនៃលោហធាតុនេះតែម្តង ត្បិតប្រាក់ទន់ស្វិតនិងជំពត់បានងាយ។

គ្រឿងប្រាក់ធ្វើតាមវិធីបីយ៉ាង គឺសិត វាយរាងដោយដៃ និងវាយពុម្ពឬជាន់ពុម្ព។ ផលិតកម្មធំៗ ដូចជានៅអឺរុបឬអាមេរិក គេប្រើម៉ាស៊ីនជាន់ពុម្ព រីឯ



វិធីសិតគឺគេធ្វើដូចសិតសំរឹទ្ធិឬស្ពាន់ដែរ ក៏ប៉ុន្តែកម្រឃើញមានដូច្នេះណាស់ យើងគិតថាមានតែប្រភេទបដិមាធំៗប៉ុណ្ណោះ ដោយសារគេមានការលំបាកក្នុងការវាយឡើងរាងដោយដៃ ឧទាហរណ៍ រូបព្រះគោនន្ទី ឬព្រះពុទ្ធរូបមួយចំនួនតូចដែលរក្សានៅសារមន្ទីរជាតិ ក្រុងភ្នំពេញជាដើម។ ម្យ៉ាងបើគេយកប្រាក់ទៅសិតឃើញថាខាតប្រាក់ផង ហើយប្រាក់បើគិតតាមទ្រឹស្តីគីមីនៃលោហធាតុនេះឃើញថា ប្រាក់ដែលសិតងាយរងប្រតិកម្មអុកស៊ីតនិងធ្វើឲ្យប្រាក់ឡើងខ្មៅ។ ផ្ទុយទៅវិញ វត្ថុដែលធ្វើដោយដៃ មានរូបរាងគាប់ភ្នែកណាស់ ដោយសារមានក្បាច់រស់រវើកនិងផុសឡើងក្រឡោតល្អ មិនក្រាបស្លឹកដូចវត្ថុជាន់ពុម្ពឬសិតទេ។ វត្ថុធ្វើដោយដៃត្រូវធ្វើឡើងច្រើនដំណាក់កាលណាស់ ហើយទាមទារក្បួនខ្នាតត្រឹមត្រូវនិងឧបករណ៍ផ្សេងៗទៅតាមដំណាក់កាលនីមួយៗផង។ ដូច្នេះហើយបានជានៅតាមភូមិស្រុកដែលធ្វើគ្រឿងប្រាក់ មនុស្សចេះតាមកម្រិតផ្សេងគ្នា។ បើពោលសង្ខេប វិធីធ្វើគ្រឿងប្រាក់មាន៤ដំណាក់កាលធំៗ៖ ១- រំលាយ និងធ្វើជាបន្ទះប្រាក់ ២- វាយដំបន្ទះប្រាក់ឲ្យចេញជារូបរាង ៣- ចាក់ជ័រនិងធ្លាក់ក្បាច់ ៤- ដុសខាត់លាងសម្អាតជាចុងក្រោយ។

### ដំណាក់កាលទី១៖ រំលាយ និងធ្វើជាបន្ទះប្រាក់

ជាទូទៅ គេពុំមានបន្ទះប្រាក់ដែលកិនស្រាប់ៗដាក់លក់តាមទីផ្សារដូចស្ពាន់ ឬទង់ដែងទេ។ ជាងនីមួយៗត្រូវចេះស្វរំលាយនិងវាយដំធ្វើជាបន្ទះដោយខ្លួនឯង។ ពីជំនាន់មុន ដំណាក់កាលនេះចំណាយពេលយូរណាស់ ត្បិតធ្វើដោយដៃទាំងស្រុង។ សព្វថ្ងៃ ដំណាក់កាលនេះងាយ និងស៊ីពេលតិចជាងមុនឆ្ងាយ ដោយសារគេមានម៉ាស៊ីនជំនួសដៃខ្លះៗ។ ប្រាក់ដើមដែលទិញមកពីផ្សារឬពីហាងមាស ជាប្រាក់គ្រាប់ឬប្រាក់ដុំ។ កាលពុំទាន់មានប្រាក់គ្រាប់ ហើយប្រាក់ខ្សត់ផង គេច្រើនរំលាយគ្រឿងប្រាក់ចាស់ៗដែលបាក់បែកមកប្រើម្តងទៀត ឬពីកាក់ប្រាក់សម័យមុនៗ។ ប្រាក់ទាំងនេះមានកម្រិតសុទ្ធផ្សេងគ្នា លើកលែងតែកាក់ប្រាក់ដែលសុទ្ធល្អ។ ដូច្នេះពេលរំលាយនេះ ក៏ជាពេលដែលបន្សុទ្ធប្រាក់ដែរ។ ក្នុងដំណាក់កាលដំបូងនេះ គេចែកជា២ដំណាក់បន្តបន្ទាប់ទៀត គឺរំលាយប្រាក់

និងដំធ្វើជាបន្ទះប្រាក់។ ដំណាក់កាលនេះក៏ជាពេលដែលគេត្រូវសម្រេចចិត្តជ្រើសរើសកម្រិតសុទ្ធនៃប្រាក់នោះត្រឹមណាផង។

## រំលាយប្រាក់

ជាគោលការណ៍ ប្រាក់សុទ្ធរលាយពេលដែលសីតុណ្ហភាពឡើងដល់ ៩៦១,៧៨អង្សា។ ដើម្បីធ្វើឲ្យប្រាក់ឆាប់ក្តៅស្មើក្នុងពេលរំលាយ គេត្រូវកាត់ប្រាក់ជាកម្ទេចតូចៗ។ ដើម្បីរំលាយប្រាក់ គេត្រូវមានឧបករណ៍ចាំបាច់មួយចំនួនដូចជាចង្ក្រាន ស្នប់ បាវ ចានដី ឬពុម្ពសម្រាប់ត្រងប្រាក់រាវ[៦៧]។

- ចង្ក្រានៈ គេត្រូវមានចង្ក្រានសណ្ឋានជាចង្ក្រានផ្ពោះផ្ទាល់ដី ឬលើកខ្ពស់ត្រឹមចង្កេះស្រួលអង្គុយធ្វើការផ្សេង ដូចជាលុតនិងផ្សារ។ល។ តួចង្ក្រានអាចធ្វើដោយដីដំបូកឬរៀបឥដ្ឋ ពិសេសធន់នឹងកម្តៅ (រូបលេខ១០១)។ ផ្នែកកណ្តាលសម្រាប់ដាក់ធ្យូង។ ចង្ក្រានភ្ជាប់ទៅស្នប់មួយជាចាំបាច់ ត្បិតពេលចាប់ផ្តើមរំលាយគេត្រូវសប់ខ្យល់តតជាប់ដើម្បីឲ្យភ្លើងឆេះសន្ធោរសន្ធៅឡើង។



រូបលេខ១០១៖ ចង្ក្រាន។

---

[៦៧] ក្នុងនោះឧបករណ៍ខ្លះដែលតែងមានជាទូទៅ ដូចជាដង្កៀបចាប់ភ្លើងឬចាប់ចានរំលាយប្រាក់ជាដើម ខ្ញុំមិនចាំបាច់យកមករៀបរាប់នៅទីនេះទេ។



- ស្នប់៖ ពីមុនគេប្រើស្នប់ដៃដែលជាឈើមួយកំណាត់គេលុងឲ្យប្រហោងក្នុង ឬគេយកក្តារបួនសន្ទឹកផ្គុំគ្នាជាប្រអប់ទ្រវែង បិទសន្ទះមុខក្រោយទុកតែប្រហោងបញ្ចេញដៃស្នប់ (រូបលេខ១០២)។ ស្នប់នេះភ្ជាប់ទៅចង្ក្រានតាមបំពង់ខ្យល់មួយដែលមានរន្ធភ្ជាប់ទៅផ្នែកខាងក្រោមធ្យូង។ កាលណាគេសប់ធ្យូងដែលឆេះនោះក៏សន្ធៅឡើង។



រូបលេខ១០២៖ ស្នប់បុរាណ (រូបថតរោងជាងជួសជុលចម្លាក់ថ្មនៃសារមន្ទីរជាតិ ភ្នំពេញ)។

សព្វថ្ងៃ គេលែងប្រើស្នប់ប្រភេទនេះទៀតហើយ។ មានឧបករណ៍ម្យ៉ាងដែលមានកង្ហារខាងក្នុង។ កង្ហារនោះអាចវៃដោយដៃ ឬដោយម៉ូទ័រ (រូបលេខ១០៣-១០៤) ហើយក៏បញ្ជូនខ្យល់តាមបំពង់វែងដែលភ្ជាប់ទៅចង្ក្រាន។ តាំងពីពេលមានឧបករណ៍នេះមក ជាងចំណេញពេលនិងកម្លាំងជាងមុនច្រើន ហើយប្រាក់ក៏រលាយស្មើបានល្អ ដោយសារមានកម្តៅគ្រប់គ្រាន់និងស្មើល្អ។ ក្រៅពីភ្លើងចេញពីចង្ក្រាន សព្វថ្ងៃជាងមានឧបករណ៍មួយផ្សេងទៀតដែលគេហៅថាខ្សៀ ជាជំនួយដើម្បីផ្លុំបញ្ចេញភ្លើងពីលើ។ តាមពិតទៅខ្សៀនេះគេប្រើសម្រាប់ផ្សា តែដោយសារភ្លើងដែលចេញពីខ្សៀមានកម្តៅខ្លាំង ដូច្នេះក្នុងពេលរំលាយប្រាក់គេតែងប្រើភ្លើងខ្សៀនេះជួយពីលើ។



រូបលេខ១០៣៖ ស្នប់ប្រើកង្ហារវៃដៃ។



រូបលេខ១០៤៖ ស្នប់ប្រើម៉ូទ័រកែច្នៃពីកង្ហារម៉ាស៊ីនត្រជាក់ឡាន។

- បាវ៖ ជាភាជន៍ក្រាស់មួយប្រភេទរាងក្រឡូមដូចត្បាល់បុក ជាងប្រើសម្រាប់ដាក់ប្រាក់រំលាយ។ ភាជន៍នេះធន់នឹងកម្ដៅ (រូបលេខ១០៥-១០៦)។ ពីមុនស្មូនទៅកំពង់ឆ្នាំងក៏ធ្លាប់ធ្វើឧបករណ៍នេះសម្រាប់លក់មកឲ្យជាងប្រាក់ដែរ តែសព្វថ្ងៃគេទិញពីផ្សារដែលគេនាំមកពីថៃឡង់ដ៍។ ភាជន៍នេះគេហៅថា "បាវ"។ បាវនីមួយៗគេប្រើច្រើនដងរហូតទាល់តែបែកឬប្រេះទើបគេចោល។


រូបលេខ១០៥៖ បាវរំលាយប្រាក់។


រូបលេខ១០៦៖ បាវរំលាយស្ពាន់។

- ចានឬពុម្ព៖ ប្រាក់ដែលរលាយហើយ គេត្រូវចាក់ចូលចានដីសំប៉ែតមួយទុកឲ្យប្រាក់កកជាបន្ទះសិន មុននឹងដំឬកិនឲ្យស្ដើង។ សព្វថ្ងៃគេច្នៃធ្វើពុម្ពដែកជាប្រអប់បួនជ្រុងដែលមានប្រឡោះកណ្ដាលសម្រាប់ចាក់ប្រាក់រាវចូល។ ពុម្ពនេះបញ្ឈរមានមុខម្ខាងជាសន្ទះបិទបើកបាន (រូបលេខ១០៧-១០៨)។


រូបលេខ១០៧៖ ពុម្ពសម្រាប់ចាក់ធ្វើបន្ទះប្រាក់។


រូបលេខ១០៨៖ ពុម្ពសម្រាប់ចាក់ធ្វើបន្ទះប្រាក់។ គេចាក់ដុំស្ពាន់។



គេកម្ររំលាយធ្វើជាបន្ទះប្រាក់ទុកណាស់ ទាល់តែពេលគេត្រូវធ្វើគ្រឿងអ្វីមួយ ព្រោះជាងដឹងថាត្រូវរំលាយទម្ងន់ប៉ុន្មានៗ។ ពេលគេរំលាយម្ដងៗ គេច្រិបប្រាក់ជាកម្ទេចតូចៗដាក់ចូលទៅក្នុងបាវ។ ក្នុងដំណាក់កាលនេះ មេជាងមិនសូវធ្វើផ្ទាល់ទេ ច្រើនតែប្រើកូនជាង ដូច្នេះពេលនេះជាពេលដែលសិស្ស ឬអ្នកមករៀនជាមួយមេជាងប្រាក់ត្រូវចាប់ផ្ដើមមេរៀនដំបូងៗ ដោយចាប់ពីវិធីរំលាយប្រាក់។ កិច្ចការរំលាយប្រាក់នេះសំខាន់ណាស់ដែរ ត្បិតជាពេលដែលគេសម្រេចថាត្រូវបន្សុទ្ធប្រាក់ត្រឹមកម្រិតណា។ ពេលរំលាយ គេយកបាវដែលមានកម្ទេចប្រាក់ក្នុងនោះដាក់ឲ្យចំភ្លើងល្អ ហើយសប់ខ្យល់មិនឲ្យដាច់ដើម្បីឲ្យភ្លើងឆេះឡើង (រូបលេខ១០៩) ពីលើជាងក៏បញ្ចេញភ្លើងពីខ្សៀ ខាងក្រោមភ្លើងក៏សន្ធោខ្លាំង ប្រាក់ចាប់រលាយពេលដែលឡើងដល់សីតុណ្ហភាព៩៦១,៧៨អង្សា (រូបលេខ១១០)។ ប្រាក់រលាយស្មើសាច់ហើយ គេត្រូវចាក់ចូលទៅចានដីឬពុម្ពដែកដូចបានរៀបរាប់ខាងលើ។ ដើម្បីកុំឲ្យប្រាក់ជាប់នឹងចានឬពុម្ព គេត្រូវលាបប្រេងឬក្រមួនបន្តិចៗ។ រូបលេខ១១១ ជាដុំប្រាក់ដែលបានពីរំលាយ។


រូបលេខ១០៩៖ រំលាយប្រាក់។


រូបលេខ១១០៖ ដោយមានភ្លើងចេញពីខ្សៀខាងលើផង ប្រាក់ក៏រលាយពេលកម្ដៅឡើងដល់ ៩៦១,៧៨អង្សា។


រូបលេខ១១១៖
ដុំប្រាក់ដែលបានពីរំលាយ។

ប្រាក់គ្រាប់ដែលគេទិញពីផ្សារដែលនាំមកពីសិង្ហបុរីច្រើនតែសុទ្ធលើសពី៩៥ភាគរយស្រាប់ មិនចាំបាច់ដេញប្រាក់ឲ្យសុទ្ធក៏បាន។ តែបើប្រាក់នាំចូលពីវៀតណាមនៅមានសំណច្រើន។ ដូច្នេះ បើចង់ឲ្យសុទ្ធគេត្រូវដេញសំណចេញខ្លះ។ ដើម្បីឲ្យប្រាក់សុទ្ធល្អ គេត្រូវទុកប្រាក់ដែលរលាយឲ្យនៅយូរបន្តិចដើម្បីឲ្យសំណដែលតែងមានក្នុងប្រាក់ភាយចេញ។ ដូច្នេះ ប្រាក់វៀតណាមកាលណារំលាយរួចតែងបាត់ទម្ងន់ខ្លះ។ ដូច្នេះហើយជាងមិនចង់យកប្រាក់ពីវៀតណាមមកធ្វើទេ ត្បិតនាំឲ្យខាត ហើយជៀសវាងម្ចាស់វត្ថុសង្ស័យថាជាងមានការកែបន្លំផង។

## ដំនិងកិនជាបន្ទះប្រាក់

ប្រាក់ដែលកកក្នុងចានឬពុម្ពនៅពុំទាន់ស្មើសាច់ទេ ផ្នែកខ្លះមានជាប់កម្ទេចកម្ទីផ្សេងៗ។ ដូច្នេះមុននឹងដំ ឬកិនឲ្យទៅជាបន្ទះស្តើងគេត្រូវលត់ច្រើនសាររហូតប្រាក់ស្មើសាច់។ ធ្វើដូច្នេះសាច់ប្រាក់ស្វិត និងហាប់ណែន និងអាចវាយដំធ្វើវត្ថុផ្សេងៗលែងមានប្រេះស្រាំ។ ពីមុនគេធ្វើបន្ទះប្រាក់ដោយដៃសុទ្ធសាធ ដូច្នេះជាងបន្តដំរហូតចេញជាកម្រាសមួយដែលគេចង់បានមុននឹងគេកាត់តាមពុម្ពដើម្បីវាយចេញរាងជាវត្ថុនីមួយៗ។ សព្វថ្ងៃ នៅតាមភូមិតែងមានរោងម៉ាស៊ីនកិនខ្នាតធំ២ទៅ៣កន្លែង (រូបលេខ១១២)។ ម៉ាស៊ីននេះប្រើម៉ូទ័រ ដូច្នេះជាងមិនចាំបាច់ដំដោយដៃដូចមុនទៀតទេ ពេលក៏ចំណេញហើយប្រាក់ក៏ស្មើល្អ។ ម៉ាស៊ីនប្រភេទនេះ ប្រហែលលេចឡើងក្នុងរវាងទសវត្សរ៍១៩៥០ ពេលដែលកើតមានសិប្បកម្មប្រើកម្លាំងពលកម្មច្រើន ហើយការផលិតពេលនោះមានទ្រង់ទ្រាយធំផង។ បច្ចុប្បន្នម្ចាស់រោងម៉ាស៊ីនស៊ីឈ្នួលកិនប្រាក់ផង ធ្វៀតរំលាយស្ពាន់ ទង់ដែងជាខ្សែភ្លើង ជាសម្បកគ្រាប់កាំភ្លើងដែលទិញពីអេតចាយមកធ្វើជាបន្ទះស្ពាន់ទុកលក់ផង (រូបលេខ១១៣)។

ប្រាក់ដែលបានពីដំលត់ច្រើនសារហើយ ជាងជួលគេកិនបន្តដោយគ្រាន់តែសរសេរទុកលើបន្ទះប្រាក់នោះថាត្រូវកិនកម្រាស់ណានិងទំហំមុខប៉ុណ្ណាជាការស្រេច។ ធម្មតាគេត្រូវទុកឲ្យក្រាស់ជាងវត្ថុដែលត្រូវធ្វើបន្តិច ត្បិតពេលយកមកផ្ទះវិញ ជាងកាត់យកតែទំហំណាមួយឲ្យសមល្មមសម្រាប់វត្ថុដែលត្រូវធ្វើមកកិននឹងម៉ាស៊ីនខ្នាតតូចរវៃដោយដៃ ដែលជាងតែងមានគ្រប់ផ្ទះ (រូបលេខ១១៤)។





រូបលេខ១១២៖ ដុំប្រាក់ ឬស្ពាន់ គេយកទៅផែជាបន្ទះដោយម៉ាស៊ីនប្រើម៉ូទ័រ។



រូបលេខ១១៣៖ បន្ទះស្ពាន់ដែលគេផែទុកលក់។

រូបលេខ១១៤៖
ម៉ាស៊ីនកិនដោយដៃដែលជាងប្រាក់
មាននៅតាមផ្ទះរៀងៗខ្លួន។



## ដំណាក់កាលទី២៖ ឡើងរាង

### វាយរាងដោយដៃ

ប្រាក់ដែលបានពីកិនចុងក្រោយនឹងម៉ាស៊ីនដៃនេះក្តី ក៏គង់ជាងយកមកដុតដំបន្ថែមបន្តយម្តងទៀត ពេលវាយរាងជាក់ស្តែង (រូបលេខ១១៥)។ ក្នុងដំណាក់កាលជាបន្តនេះ ជាងហៅថា “ឡើងក្បាលដែក”។ ដំណាក់កាលមុនៗមេជាងអាចប្រើកូនឈ្នួលដែលមកស្នាក់នៅសុំរៀនធ្វើបាន តែពេលនេះមេជាងត្រូវធ្វើខ្លួនឯង។ ជាងដែលចេញពីសាលារចនា ឬរៀនពីគ្រូផ្សេងៗ គេចាត់ទុកថាចេះចប់សព្វគ្រប់ទៅប្រកបរបរខ្លួនបាន លុះត្រាតែចេះឡើងក្បាលដែក។ ជាងនៅភូមិពោធិតូចនិងនៅព្រែកក្តាមមានតិចតួចប៉ុណ្ណោះដែលចេះឡើងក្បាលដែកបានស្ទាត់ជំនាញ ជាពិសេសជាងនៅពោធិតូច ដោយសារនៅទីនេះគេធ្វើគ្រឿងរូបសត្វ ឬផ្លែឈើដែលមានគន្ទាក់កាច់កេវច្រើន។ ជាងខ្លះចេះធ្វើតែគ្រឿងដដែលៗ។

ដូច្នេះហើយ ជាងណាដែលមិនសូវស្ទាត់ដូច្នេះ ច្រើនតែទទួលម៉ៅធ្វើគ្រឿងណាមួយផ្តាច់មុខពីមេជាងណាមួយក្នុងភូមិ។ មុននឹងឡើងក្បាលដែក ជាងត្រូវកាត់បន្ទះប្រាក់តម្រូវតាមពុម្ពក្រដាសជាមុនសិន (រូបលេខ១១៦)។ គ្រឿងនីមួយៗគេត្រូវធ្វើទៅតាមទម្ងន់និងខ្នាតមួយដែលមើលទៅសមភ្នែក។ ពុម្ពនេះគេតែងរក្សាទុកជាគម្រូធ្វើក្រោយៗទៀត (រូបលេខ១១៧)។ ដូច្នេះ យើងតែងឃើញគម្រូរូបសត្វទាំង១២តាមឆ្នាំនីមួយៗ។ ជាងដែលរាប់ថាពូកែបាន គឺអាចវាយរាងវត្ថុមួយដែលខ្លួនមិនធ្លាប់ធ្វើពីមុនមក ឬទំហំតាមចិត្តម្ចាស់វត្ថុមករកឲ្យធ្វើ។ ទោះបីយ៉ាងណា ពេលជួបនឹងវត្ថុថ្មីឬសត្វអ្វីថ្មី ជាងតែងរកគម្រូមើល បើពុំនោះទេ ជាងត្រូវសូនរូបពីដីឥដ្ឋមើលជាមុន។ កាលណាមើលទៅសមភ្នែកហើយ ទើបជាងយករូបដីនេះជាគម្រូ។ សព្វថ្ងៃងាយស្រួលជាងមុនច្រើន ត្បិតជាងអាចរកទិញរូបសត្វផ្សេងៗជាតុក្កតាក្មេងលេងមកមើលជាគម្រូ។ ក្នុងដំណាក់កាលឡើងក្បាលដែក ជាងត្រូវការឧបករណ៍ចាំបាច់ពីរ គឺប្រដាយនិងញញួរវាយរាង។ ឧបករណ៍ទាំងពីរនេះរកកំណត់ថាចំនួនប៉ុន្មានពុំបាន ត្បិតជាងតែងធ្វើតម្រូវទៅតាមទេសកាលនៃវត្ថុដែលត្រូវមានរាងរៅផ្សេងៗ។


រូបលេខ១១៥៖ ជាងដំប្រាក់បន្ថែមឲ្យស្តើងតាមចិត្តចង់បានមុននឹងឡើងក្បាលដែក។


រូបលេខ១១៦៖ កាត់ពុម្ព។




រូបលេខ១១៧៖ ពុម្ពក្រដាសដែលជាងរក្សាទុកប្រើលើកក្រោយ។

- ប្រដាយ៖ ជាទ្រនាប់ដែករាងអក្សរ “ T ” (រូបលេខ១១៨) នៅខាងចុងទាំងសងខាង គេដំឲ្យស្រួចចុងនិងឲ្យចេញជាគន្ទាក់ផ្សេងៗ។ ខាងគល់ដែកគេដាក់គៀបជាមួយទ្រនាប់ឈើ ហើយចុងម្ខាងនៃដែកនោះ ក៏ស៊កគៀបនឹងទ្រនាប់ឈើដែរ រីឯចុងម្ខាងទៀតស្ថិតក្នុងស្ថានភាពបញ្ឈិតតាមមុម៤៥អង្សា (រូបលេខ១១៩)។ ប្រដាយមានទំហំតូចធំច្រើនមុខ រកកំណត់ថាជាងម្នាក់ៗត្រូវមានប្រដាយចំនួនប៉ុន្មានមិនបាន។ ជួនកាលជាងត្រូវធ្វើប្រដាយបន្ថែម ជួនកាលទៀតប្រដាយដដែល ជាងយកមកវាយដំប្តូររាងតាមដែលពេលត្រូវការម្តងៗក៏សឹងមាន។ ពេលឡើងរាង ជាងយកបន្ទះប្រាក់មកដាក់ពីលើប្រដាយ រួចយកញញួរដំពីលើឲ្យចេញជារាងរៅផ្សេងៗទៅតាមគន្ទាក់នៃចុងប្រដាយ។ ដូច្នេះជាងត្រូវមានញញួរផ្សេងៗសម្រាប់វាយរាងជាគូគ្នានឹងប្រដាយ។


រូបលេខ១១៨៖ ប្រដាយ។


រូបលេខ១១៩៖ ប្រដាយដែលគេដាក់ជាមួយទ្រនាប់។

- ញញួរវាយរាង៖ ដូចជ្រាបស្រាប់ហើយ គ្រឿងប្រាក់ខ្មែរធ្វើឡើងដោយដៃទាំងស្រុងៗ ប្រដាប់តែមួយមិនអាចឲ្យគេធ្វើអ្វីបានទេ ជាងត្រូវធ្វើញញួរដែលមានក្បាលនិងទំហំផ្សេងៗគ្នាតម្រូវតាមគ្រឿងនីមួយៗដែរ បើពោលឲ្យសង្ខេបជាងត្រូវមានញញួររើសរាង ញញួរដុក និងញញួរដែលមានក្បាលមូល (ជាងហៅថាញញួរក្បាលស្វា) សម្រាប់វាយចេញរាងប៉ោងឬក្រឡូម (រូបលេខ១២០-១២៥)។



រូបលេខ១២០



រូបលេខ១២១



រូបលេខ១២២



រូបលេខ១២៣



រូបលេខ១២៤



រូបលេខ១២៥

រូបលេខ១២០-១២៥៖ ញញួរដែលមាននាទីផ្សេងៗគ្នា។



- ត្រី៖ ក្នុងដំណាក់កាលឡើងក្បាលដែកនេះ ជាងត្រូវផ្សារភ្ជាប់តាមផ្នែកខ្លះៗជាមុនសិនៗ បន្ទះប្រាក់ដែលកាត់តាមពុម្ពរួចហើយ ជាងត្រូវពត់ និងផ្សារភ្ជាប់គ្នាសិនៗ ជួនកាលគ្រឿងមួយត្រូវធ្វើផ្សេងៗគ្នាជាបំណែកក្បាលផ្សេង ជើងផ្សេង នេះមិននិយាយដល់ផ្នែកតូចតាចខ្លះ ដូចជាត្រចៀក ស្នែងត្រូវផ្សារភ្ជាប់តាមក្រោយផងៗ ដូច្នេះជាងត្រូវការទឹកអន្សាដែលគេហៅថា " ត្រី " (រូបលេខ១២៦)។ ជាងត្រូវចេះធ្វើត្រីផ្សារគ្រប់ៗគ្នាៗ ត្រីផ្សារប្រាក់ខុសត្រីផ្សារស្ពាន់ៗ ត្រីផ្សារជាល្បាយនៃទឹកអន្សាលាយជាមួយកម្ទេចប្រាក់ ឬកម្ទេចស្ពាន់ៗ ពេលផ្សារគេលាបត្រីពីលើមុខតំណ (រូបលេខ១២៧-១២៨)។ បន្ទាប់មកដាក់វត្ថុនោះ លើភ្លើងចង្ក្រានឲ្យបំភ្លើងល្អនិងទុកឲ្យសាច់ប្រាក់ក្ដៅសិនៗ កាលណាលោហៈក្ដៅដល់កម្រិតហើយ ជាងក៏យកខ្សៀផ្លុំភ្លើងពីលើៗ ភ្លើងចេញពីខ្សៀក្ដៅខ្លាំងណាស់ ដោយសារមានចំហេះពីប្រេងកាតនិងសម្ពាធខ្យល់ដែលគេសប់បញ្ចូលក្នុងកំប៉ុងប្រេងមួយដែលភ្ជាប់មកស្នប់និងទៅខ្សៀធ្វើឲ្យភ្លើងឡើងពណ៌ខៀវៗ ត្រីដែលមានកម្ទេចប្រាក់ឬស្ពាន់ក៏រលាយ ហើយទៅស៊ីគ្នាជាមួយមុខតំណៗ



រូបលេខ១២៦៖ ទឹកអន្សា ហៅថា "ត្រី"ៗ



រូបលេខ១២៧៖ លាបត្រីលើ មុខតំណៗ



រូបលេខ១២៨៖ លាបត្រីលើ មុខតំណៗ

## វាយពុម្ព

សព្វថ្ងៃជាងច្រើនប្រើពុម្ពញីឈ្មោលសម្រាប់ដំឲ្យចេញជារាងស្រាប់ៗៗ ដូច្នេះយើងឃើញមានពុម្ពរូបសត្វ ឬផ្លែឈើតាមទំហំផ្សេងៗគ្នា (រូបលេខ១២៩-១៣០)ៗ ពុម្ពនេះគេធ្វើពីសំលោហៈអង់ទីមាន់ (និមិត្តសញ្ញាគីមីនៃសំលោហៈនេះគឺ Sb) ដែលគេរំលាយពីគ្រឿងម៉ាស៊ីនឡានឬម៉ូតូ ជាពិសេសកាបៀរ៉ាទ័រឡាន



រូបលេខ១២៩៖ ពុម្ពវាយរាងរូបសត្វ។



រូបលេខ១៣០៖ ពុម្ពវាយរាងរូបសត្វ។

ឬម៉ូតូ។ ពុម្ពនីមួយៗប្រើបានយូរគ្រែលដែរ គឺគេប្រើរហូតទាល់តែបែកទើបយកទៅរំលាយធ្វើម្តងទៀត។ ពុម្ពនេះ ជាងត្រូវចេះធ្វើខ្លួនឯង។ ទោះបីយ៉ាងណាក៏ជៀសមិនរួចពីវាយរាងនឹងដៃបន្ថែមដែរ ត្បិតរាងចេញពីពុម្ពមិនផុសល្អឡើយ។

មកដល់ត្រឹមនេះ យើងឃើញថាជាងប្រាក់ត្រូវមានឯកទេសផ្សេងៗច្រើនចូលគ្នា។ ពីមុនមកជាងនីមួយៗត្រូវចេះធ្វើឧបករណ៍ចាំបាច់ផ្សេងៗសម្រាប់ការផលិត។ សព្វថ្ងៃជាងដែកខ្លះមករកស៊ីជាមួយជាងប្រាក់។ ជាងដែកទាំងនោះផលិតតែឧបករណ៍សម្រាប់ជាង មានដូចជាញញួរ ដែកទ្រនាប់ ប្រដាប់ និងដែកឆ្លាក់។ល។

## ដំណាក់កាលទី៣៖ ចាក់ជ័រ

គ្រឿងដែលឡើងរាងរួច គេមិនទាន់យកទៅឆ្លាក់បានទេ គេត្រូវចាក់ជ័របំពេញផ្ទៃខាងក្នុងជាទ្រនាប់សិន (រូបលេខ១៣១-១៣២)។ "ជ័រ" ជាពាក្យជាងប្រាក់នៅតំបន់កំពង់ហ្លួងនិងកោះចិនហៅសំដៅលើល្បាយដែលគេបំពេញក្នុងគ្រឿងប្រាក់ពេលឆ្លាក់។ ជាងនៅសាលារចនានិងជាងមាសហៅវត្ថុដូចគ្នានេះថា "ព្រមរ"។ ជ័រនេះមានសមាសធាតុបីសំខាន់ គឺជ័រចុង ដីដំបូកឬដីលែង និងខ្លាញ់ត្រី។ ជាងគ្រប់គ្នារាប់ទាំងស្រីៗដែលចេះត្រឹមតែការងារឆ្លាក់ក៏ត្រូវតែចេះស្ងោរលាយជ័រនេះដែរ។ គេត្រូវស្ងោរលាយបញ្ចូលគ្នាតាមសមាមាត្រ៖ ជ័រចុង១គ.ក្រ. ដី១គ.ក្រ. និងខ្លាញ់ត្រីកន្លះគ.ក្រ.។





រូបលេខ១៣១៖ ចាក់ជ័រមុននឹងឆ្លាក់។



រូបលេខ១៣២៖ ចាក់ជ័រមុននឹងឆ្លាក់។

ដូច្នេះបើគេស្ងោក្នុងបរិមាណច្រើន គេត្រូវអនុលោមតាមសមាមាត្រនេះ គួបផ្សំនឹងការជាក់ស្តែងផង។ បានសេចក្តីថា គេត្រូវមើលយ៉ាងណាមិនឲ្យរឹងខ្លាំង នាំឲ្យជ័រនោះស្រួយ តែបើទន់ខ្លាំងក៏ឆ្លាក់មិនកើត អាចនាំឲ្យផុងសាច់ប្រាក់ឬគ្មានកម្លាំងទប់សាច់ប្រាក់បាន។ ការដែលទន់ខ្លាំងឬរឹងខ្លាំង គេអាចថែមឬថយខ្លាញ់ត្រី ឬជ័រតាមការជាក់ស្តែង។ ជ័រនេះគេប្រើបានច្រើនសារហូតកាលណាឡើងរឹងខ្លាំង ឬលែងទន់ល្អតដោយសារជាតិខ្លាញ់ត្រីនិងជ័រចុងឆេះអស់ ទើបប្រើលែងកើត។ ហេតុនេះហើយ គេត្រូវឧស្សាហ៍ថែមខ្លាញ់ត្រីឬជ័រចុង។ ជ័រដែលគេស្ងោរួសព្វសាច់ហើយ គេចាក់បញ្ចូលផ្នែកខាងក្នុងនៃវត្ថុដែលត្រូវឆ្លាក់ រួចបន្ទាប់មកគេបិទភ្ជាប់នឹងឈើមួយកំណាត់ខ្លី (រូបលេខ១៣៣-១៣៤)។ ឈើនេះគេស៊កបញ្ចូលក្នុងរន្ធកីសម្រាប់ទប់ឲ្យមានលំនឹង និងបង្វិលបានពេលឆ្លាក់ក្បាច់



រូបលេខ១៣៣៖ គ្រឿងប្រាក់ដែលចាក់ជ័ររួច។



រូបលេខ១៣៤៖ គ្រឿងប្រាក់ដែលចាក់ជ័ររួច។

(រូបលេខ១៣៥)។ ការឆ្លាក់ក្បាច់ក៏ប្រែប្រួលតាមរូបរាងវត្ថុនីមួយៗដែរ បើជាវត្ថុមានផ្ទៃស្មើ គេពុំចាំបាច់ប្រើកីទេ។



រូបលេខ១៣៦៖
គ្រឿងដែលចាក់ជ័ររួចសិកបញ្ចូលក្នុងរន្ធកីដើម្បីឆ្លាក់។

## ដំណាក់កាលទី៤៖ ឆ្លាក់ក្បាច់

ការឆ្លាក់ក្បាច់លើគ្រឿងប្រាក់មិនដូចគេឆ្លាក់លើឈើឬថ្មទេ ព្រោះគេមិនដាប់ផ្នែកណាមួយចេញទេ គឺគេត្រូវដិសង្កត់ផ្នែកដែលគ្មានក្បាច់ឲ្យលិបជ្រៅចូលក្នុង ដែលភាសាជាងហៅថា "ស្ពាន" គឺជាផ្ទៃដែលគ្មានក្បាច់។ ដើម្បីឲ្យក្បាច់ផុសល្អ គ្រឿងខ្លះដែលឆ្លាក់ម្តងហើយគេត្រូវរំលាយជ័ររួច ប្រទុលពីខាងក្នុង ទើបបំពេញជ័រឡើងវិញ ហើយចាប់ដិសង្កត់ឲ្យសាច់ប្រាក់លិបម្តងទៀត។ គេអាចធ្វើដូច្នេះច្រើនដង ហើយម្តងៗគេហៅថា "មួយភ្លើង" ឬ "ពីរភ្លើង" ទៅតាមចំនួនដែលគេបានធ្វើ។ សព្វថ្ងៃជាងនៅកំពង់ហ្លួង ឬកោះចិនធ្វើតែមួយភ្លើងប៉ុណ្ណោះកម្រលើសពីនេះណាស់ លើកលែងតែជាងនៅភ្នំពេញ (រូបលេខ១៣៦-១៣៧)។



រូបលេខ១៣៦៖ គ្រឿងដែលគេត្រូវឆ្លាក់២ភ្លើង។



រូបលេខ១៣៧៖ ផ្តិលធំដែលគេឆ្លាក់៧ភ្លើងរួចហើយមុននឹងឆ្លាក់ក្បាច់ចុងក្រោយ។